# ពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាពនៃអនុសញ្ញាស្តីពីជីវៈចម្រុះ

ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ:

ជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ យោងទៅតាមអនុសញ្ញានេះ។

បានឃើញមាត្រា ១៩ ក្នុងឃ្លាទី ៣ និងទី៤ ហើយនឹងមាត្រា ៨ (g) និង១៧នៃអនុសញ្ញានេះ។

បានឃើញសេចក្តីសំរេច II/៥ នៃសន្និសីទភាគីអនុសញ្ញាទាំងអស់ ដើម្បីធ្វើការកែសំរួលពិធីសារ ស្តីពីជីវសុវត្ថិភាព នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដោយផ្តោតការយកទុកដាក់ជាពិសេសទៅលើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃបច្ចេកវិទ្យាទំនើប ហើយអាចបង្កអោយមានឥទ្ធិពលអវិជ្ជមានដល់ការអភិរក្ស និងនិរន្តរភាពនៃការប្រើប្រាស់ធនធានជីវៈចម្រុះ ដែលកំណត់ចេញសំរាប់ធ្វើការពិចារណាទៅលើនីតិវិធីសមស្របសំរាប់ការព្រមព្រៀងដែលជូនព័ត៌មានជាមុន។

ដោយធ្វើការអះអាងជាថ្មីឡើងវិញនូវវិធានការណ៍ការពារដែលមាននៅក្នុងគោលការណ៍ទី ១៥ នៃសេចក្តីប្រកាស **Rio** ស្តីពីបរិស្ថាន និងការអភិវឌ្ឍ។

ដោយយល់ដឹងពីការរីកចំរើននៃជីវបច្ចេកវិទ្យាទំនើប និងការកើនឡើងនូវការព្រួយបារម្ភរបស់សាធារណៈពីឥទ្ធិពលអវិជ្ជមានទៅលើធនធានជីវៈចម្រុះ និងសុខភាពមនុស្ស។

ដោយទទួលស្គាល់ថា ជីវបច្ចេកវិទ្យាទំនើបមានអត្ថប្រយោជន៍យ៉ាងច្រើនសំរាប់មនុស្សលោក ប្រសិនបើត្រូវបានប្រើប្រាស់ដោយមានវិធានការណ៍សុវត្ថិភាពត្រឹមត្រូវសំរាប់បរិស្ថាន និងសុខភាពមនុស្ស។

ដោយទទួលស្គាល់ផងដែរនូវសារៈសំខាន់ដល់ប្រភពមជ្ឈមណ្ឌលដើមកំណើតរបស់មនុស្សលោក និងមណ្ឌលសេនេទិចចម្រុះ

ដោយដឹងថាសមត្ថភាពនៃប្រទេសជាច្រើននៅមានកំរិត ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីប្រឈមទល់នឹងធម្មជាតិ និងកំរិតនៃការយល់ដឹង និងសក្តានុពលហានិភ័យដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់។

ដោយទទួលស្គាល់ថាកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងបរិស្ថានត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីសំរេចអោយបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

ដោយកត់សំគាល់ផងដែរថា ពិធីសារនេះនឹងមិនត្រូវបានបកស្រាយទៅលើការឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ចនៃភាគីចុះកិច្ចសន្យានៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់។

ដោយយល់ឃើញថា រាល់ចំនុចដែលបានរៀបរាប់ខាងលើនេះ ពុំមានបំណងដាក់ពិធីសារនេះអោយរណបទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតទេ។

ភាគីចុះកិច្ចសន្យាបានឯកភាពខាងក្រោម:

មាត្រា ១

គោលបំណង

អនុលោមទៅតាមវិធានការណ៍ប្រុងប្រយ័ត្នដែលចែងនៅក្នុងគោលការណ៍ទី១៥ នៃសេចក្តីប្រកាសទីក្រុង **Rio** ស្តីពីបរិស្ថាន និងការអភិវឌ្ឍ គោលបំណងនៃពិធីសារនេះ គឺដើម្បីរួមវិភាគទានក្នុងការធានាកំរិតការពារឱ្យបានសមស្របនៅក្នុងការផ្ទេរ ការគ្រប់គ្រង និងការប្រើប្រាស់ឱ្យមានសុវត្ថិភាពនៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃជីវបច្ចេកវិទ្យាទំនើបដែលអាចនាំមកនូវផលប៉ះពាល់អវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវៈចម្រុះដោយគិតគូរអំពីហានិភ័យដល់សុខភាពមនុស្ស និងជាពិសេសផ្តោតការចាប់អារម្មណ៍សំខាន់ទៅលើចលនាឆ្លងដែនផងដែរ។

មាត្រា ២

បទបញ្ញតិទូទៅ

១. ភាគីនីមួយៗនៃពិធីសារអន្តរជាតិនេះ ត្រូវប្រកាន់យកនូវវិធានការច្បាប់ គ្រប់គ្រងរដ្ឋបាលសមស្រប និងចាំបាច់ និងវិធានការណ៍ផ្សេងៗទៀត ដើម្បីប្រតិបត្តិកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងពិធីសារនេះ។

២. ភាគីត្រូវធានាថា ការអភិវឌ្ឍ ការគ្រប់គ្រង ការដឹកជញ្ជូន ការប្រើប្រាស់ ការផ្ទេរ និងការបញ្ចេញនូវសារពាង្គកាយកែច្នៃរស់ត្រូវបានធ្វើឡើងក្នុងគោលបំណងការពារ ឬការកាត់បន្ថយហានិភ័យដល់ជីវៈចម្រុះ ដោយត្រូវគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ។

៣. ពុំមានចំនុចណាមួយនៅក្នុងពិធីសារនេះ ប៉ះពាល់ទៅលើអធិបតេយ្យភាពដែនសមុទ្ររបស់រដ្ឋទាំងអស់ដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់អន្តរជាតិនោះទេ ហើយសិទ្ធិអធិបតេយ្យភាព និងដែនសមត្ថកិច្ចដែលរដ្ឋទាំងនោះមានបញ្ជាក់នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone) របស់ខ្លួន និងកិច្ចការពារទ្វីបរបស់គេដោយផ្អែកទៅតាមច្បាប់អន្តរជាតិ ព្រមទាំងការប្រើប្រាស់សិទ្ធិ និងសេរីភាពក្នុងការធ្វើចរាចរផ្លូវទឹក និងផ្លូវអាកាសរបស់ប្រទេសនីមួយៗ ដូចមានចែងក្នុងច្បាប់អន្តរជាតិ និងបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់អន្តរជាតិពាក់ព័ន្ធនានា។

៤. គ្មានចំនុចណាមួយនៃពិធីសារនេះ ត្រូវបានបកស្រាយថាជាការដាក់កំហិតសិទ្ធិរបស់ភាគីណាមួយក្នុងការចាត់វិធានការណ៍ការពារបន្ថែមនៃការប្រើប្រាស់ និងការអភិរក្សជីវៈចម្រុះដោយនិរន្តរភាពច្រើនជាងការអំពាវនាវដែលបញ្ជាក់ក្នុងពិធីសារនេះដែលចែងថាវិធានការណ៍នេះគឺស្របទៅនឹងគោលបំណង និងបទបញ្ញត្តិនៃពិធីសារនេះ ហើយអនុលោមទៅនឹងកាតព្វកិច្ចដទៃទៀតរបស់ភាគីផ្សេងទៀតដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ។

៥. ភាគីទាំងអស់ត្រូវបានជំរុញឱ្យធ្វើការពិចារណាឱ្យបានសមស្របទៅលើជំនាញដែលមានស្រាប់ ឧបករណ៍ច្បាប់ និងការងារដែលអនុវត្តន៍ក្នុងវេទិកាអន្តរជាតិ ប្រកបដោយសមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យដល់សុខភាពមនុស្ស។

មាត្រា ៣

ការប្រើប្រាស់ពាក្យ

សំរាប់គោលបំណងនៃពិធីសារនេះ:

១. “**សន្និសីទភាគី**” មានន័យថាជាសន្និសីទនៃភាគីទាំងអស់ដែលចុះកិច្ចសន្យាទៅនឹងអនុសញ្ញា។

២. “**ការប្រើប្រាស់ក្នុងមន្ទីរពិសោធន៍**” មានន័យថាជាការប្រើប្រាស់ណាមួយ ដែលធ្វើឡើងនៅក្នុងទីតាំងសម្បទាណាមួយឧបករណ៍តំឡើង ឬរចនាសម្ព័ន្ធរូបសាស្ត្រទាក់ទងទៅនឹងសារពាង្គកាយកែច្នៃរស់

ដែលត្រូវបានត្រួតពិនិត្យ ដោយវិធានការណ៍ច្បាស់លាស់ដើម្បីកាត់បន្ថយយ៉ាងសាកសិទ្ធនូវការប៉ះពាល់ផ្ទាល់ជាមួយសារពាង្គកាយនោះ និងប៉ះពាល់លើបរិស្ថានខាងក្រៅ។

៣. "**ការនាំចេញ**" មានន័យថាចលនាឆ្លងដែនអន្តរជាតិពីភាគីមួយទៅភាគីមួយទៀត។

៤. "**អ្នកនាំចេញ**" មានន័យថាជានីតិបុគ្គល ឬរូបវន្តបុគ្គលស្ថិតនៅក្រោមដែនយុត្តាធិការនៃភាគីនាំចេញ ដែលជាអ្នកចាត់ចែងធ្វើការនាំចេញនូវសារពាង្គកាយកែច្នៃរស់។

៥."**ការនាំចូល**" មានន័យថាជាចលនាឆ្លងដែនអន្តរជាតិ ពីភាគីមួយចូលភាគីមួយទៀត។

៦. "**អ្នកនាំចូល**" មានន័យថាជានីតិបុគ្គលឬរូបវន្តបុគ្គលស្ថិតនៅក្រោមដែនយុត្តាធិការនៃភាគីនាំចូល ដែលជាអ្នកចាត់ចែងធ្វើការនាំចូលនូវសារពាង្គកាយកែច្នៃរស់។

៧. "សារពាង្គកាយកែច្នៃរស់" មានន័យថាជាសារពាង្គកាយរស់ដែលមាន ផ្ទុកនូវសារធាតុសេនេទិចថ្មីទទួលយកតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប។

៨. "**សារពាង្គកាយរស់**" មានន័យថាជាអង្គជីវសាស្ត្រទាំងឡាយណា ដែលមានសមត្ថភាពក្នុងការផ្ទេរ ឬផលិតឡើងវិញនូវសារធាតុសេនេទិច រួមទាំងសារពាង្គកាយដែលមិនអាចបន្តពូជបាន វីរុស និងវីរ៉ូអ៊ីត។

៩."**ជីវបច្ចេកវិទ្យាទំនើប**" មានន័យថាជាការអនុវត្តនូវៈ

ក) បច្ចេកទេសអាស៊ីតនុយក្លេអ៊ិចអាំងវីត្រូ (In-vitro nucleic acid techniques) រួមមានការប្រមូលផ្តុំនូវអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិក (DNA) និងការចាក់អាស៊ីតនុយក្លេអ៊ិចដោយផ្ទាល់ទៅក្នុងកោសិកា ឬសរីរាង្គ។

ខ) ការលាយចូលគ្នានៃកោសិកាដែលមិនមែនជាគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនូវការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬឧបសគ្គប្រមូលផ្តុំ ហើយដែលមិនមែនជា បច្ចេកទេសប្រើប្រាស់ នៅក្នុងការបង្កាត់ពូជ ឬការជ្រើសរើសតាមរបៀបបុរាណនោះទេ។

១០."**អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់**" ជាអង្គការបង្កើតដោយឯករាជ្យ នៅក្នុងតំបន់ ដែលសមាជិករបស់វាបានផ្ទេរសមត្ថកិច្ចទាក់ទងនឹងអភិបាលកិច្ចទៅពិធីសារនេះ ហើយដែលបានផ្តល់អំណាចត្រឹមត្រូវតាមនីតិវិធីដើម្បីចុះហត្ថលេខា ផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិកអនុលោមតាមបែបផ្ទៃក្នុង។

១១."**ចលនាឆ្លងដែន**" ជាចលនានៃសារពាង្គកាយកែច្នៃរស់ ពីភាគីមួយទៅភាគីមួយទៀត ការពារសំរាប់គោលបំណងនៃមាត្រា ១៧ និង២៤ ចលនាឆ្លងដែន គ្របដណ្តប់ដល់ចលនារវាងភាគីចុះកិច្ចសន្យា និងភាគីមិនចុះកិច្ចសន្យា។

## មាត្រា ៤

## វិសាលភាព

ពិធីសារនេះត្រូវអនុវត្តន៍ចំពោះចលនាឆ្លងដែន ការស្នាក់បណ្តោះអាសន្ន ការគ្រប់គ្រង និងការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ដែលអាចបង្កឱ្យមានផលប៉ះពាល់អាក្រក់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ដោយគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ។

## មាត្រា ៥

## ឱសថកម្ម

ថ្វីបើមានចែងនៅក្នុងមាត្រា ៤ ខាងលើ និងដោយពុំបណ្តាលឱ្យប៉ះពាល់ទៅនឹងសិទ្ធិនៃភាគីណាមួយទាក់ទងនឹងបញ្ហាសារពាង្គកាយកែច្នៃរស់ ការវាយតំលៃហានិភ័យមុននឹងធ្វើសេចក្តីសំរេចលើការនាំចូល ពិធីសារនេះមិនត្រូវអនុវត្តន៍

ចំពោះចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ដែលជាឱសថសំរាប់មនុស្សដែលត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង អន្តរជាតិ ឬអង្គការអន្តរជាតិនានា។

មាត្រា ៦

ការសំចតបណ្តោះអាសន្ន និងការប្រើប្រាស់ក្នុងមន្ទីពិសោធន៍

១. ថ្វីបើមានចែងនៅក្នុងមាត្រា ៤ ខាងលើ និងដោយពុំបណ្តាលឱ្យប៉ះពាល់ទៅនឹងសិទ្ធិនៃភាគីណាមួយលើ ការសំចតបណ្តោះអាសន្ន ដើម្បីត្រួតពិនិត្យការដឹកជញ្ជូននៃសារពាង្គកាយកែច្នៃរស់ ឆ្លងកាត់ដែនដីរបស់ភាគីនោះ និង ដើម្បី ជូនព័ត៌មានដល់បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព នូវសេចក្តីសំរេចរបស់ភាគីនោះទាក់ទងនឹងមាត្រា ២ កថាខ័ណ្ឌទី ៣ ស្តីពីការសំចតបណ្តោះអាសន្នតាមដែនដីខ្លួននូវនៃសារពាង្គកាយកែច្នៃរស់ណាមួយបទប្បញ្ញត្តិ នៃពិធីសារនេះដោយគោរព ទៅ

តាមនីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុននឹងមិនត្រូវបានអនុវត្តន៍លើការសំចតបណ្តោះអាសន្ននៃសារពាងកាយកែច្នៃរស់ នោះទេ។

២. ថ្វីបើមានចែងនៅក្នុងមាត្រា៤ ខាងលើនិងដោយពុំបណ្តាលឱ្យប៉ះពាល់នឹង សិទ្ធិនៃភាគីណាមួយដែលជា កម្មវត្ថុ នៃការវាយតំលៃហានិភ័យលើរាល់សារពាង្គកាយ កែច្នៃរស់ទាំងអស់មុននឹងធ្វើសេចក្តីសំរេចលើការនាំចូល និងដើម្បី កំណត់ បទដ្ឋានសំរាប់ការប្រើប្រាស់ក្នុងមន្ទីពិសោធន៍នៅក្នុងដែនយុត្តាធិការរបស់ខ្លួន "បទប្បញ្ញត្តិ នៃពិធីសារនេះដោយគោរពទៅ តាម នីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុន នឹងមិនត្រូវអនុវត្តន៍លើ ចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ចំពោះការប្រើ ប្រាស់ ក្នុងមន្ទីពិសោធន៍ ដែលត្រូវបានអនុវត្តន៍ស្របទៅតាមបទដ្ឋានស្តង់ដាររបស់ភាគីនាំចូល។

មាត្រា ៧

ការអនុវត្តនីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុន

១. យោងមាត្រា ៥ និង៦ នីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុនក្នុងមាត្រា ៨ ១០ និង១២ ត្រូវអនុវត្តន៍ ឱ្យបានមុនពេលចលនាឆ្លងដែនដោយចេតនាដំបូងនៃសារពាង្គកាយកែច្នៃរស់ ត្រូវបានគេនាំចូលដោយចេតនាទៅក្នុងបរិស្ថាន របស់ភាគីនាំចូល។

២. "ការនាំចូលដោយចេតនាទៅក្នុងបរិស្ថាន" ក្នុងកថាខ័ណ្ឌទី ១ ខាងលើ មិនសំដៅលើសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាចំណីអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ។

៣. មាត្រា ១១ ត្រូវអនុវត្តន៍មុនចលនាឆ្លងដែនដំបូងនៃសារពាង្គកាយរស់ដែលកែច្នៃសំរាប់ការប្រើប្រាស់ដោយ ផ្ទាល់ជាចំណីអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ។

៤. នីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុនមិនត្រូវអនុវត្តន៍ចំពោះចលនាឆ្លងដែនដោយចេតនានៃសារពាង្គកាយ កែច្នៃរស់ ដែលបានកំណត់នៅក្នុងសេចក្តីសំរេចនៃសន្និសីទភាគី ដែលជាកិច្ចប្រជុំរវាងភាគីទាំងអស់ដែលចុះកិច្ចសន្យាទៅនឹង ពិធីសារនេះ ដែលមិនទំនងជាមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ព្រមទាំងគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ។

## មាត្រា ៨

## ការជូនដំណឹង

១. ភាគីនាំចេញ ត្រូវជូនដំណឹង ឬតំរូវឱ្យអ្នកនាំចេញធ្វើលិខិតជូនព័ត៌មានជាលាយលក្ខណ៍អក្សរដល់អាជ្ញាធរមានសមត្ថកិច្ចជាតិនៃភាគីនាំចូលមុននឹងធ្វើចលនាឆ្លងដែនដោយចេតនានៃសារពាង្គកាយកែច្នៃរស់ ដែលមានចែងនៅក្នុងមាត្រា ៧ កថាខ័ណ្ឌទី ១ ។ ការជូនដំណឹងនេះយ៉ាងហោចណាស់ត្រូវមានព័ត៌មានដូចដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី ១ ។

២. ភាគីនាំចេញត្រូវធានាថា មានតំរូវការតាមផ្លូវច្បាប់មួយ ដើម្បីធានាភាពត្រឹមត្រូវនៃព័ត៌មានដែលបានផ្តល់ជូនដោយអ្នកនាំចេញ។

## មាត្រា ៩

## ការបញ្ជាក់ពីការទទួលបានសេចក្តីជូនព័ត៌មាន

១. ភាគីនាំចូលត្រូវបញ្ជាក់ពីការទទួលបាននូវសេចក្តីជូនព័ត៌មានជាលាយលក្ខណ៍អក្សរពីអ្នកជូនដំណឹង នៅក្នុងរយៈពេល ៩០ថ្ងៃ បន្ទាប់ពីទទួលបានលិខិតនោះ។

២. ការបញ្ជាក់ពីការទទួលបាននូវសេចក្តីជូនដំណឹងនោះត្រូវបរិយាយពីៈ

ក. កាលបរិច្ឆេទនៃការទទួលសេចក្តីជូនព័ត៌មាន

ខ. ថាតើសេចក្តីជូនព័ត៌មាននេះមាន (Prima Facie) ព័ត៌មានដែលមានចែងនៅក្នុងមាត្រា ៨ ដែរឬទេ

គ. ថាតើដំណើរការនេះស្របទៅនឹងក្របខ័ណ្ឌច្បាប់ក្នុងប្រទេសនៃភាគីនាំចូល ឬស្របទៅនឹងនីតិវិធីមានចែងនៅក្នុងមាត្រា ១០ ដែរឬទេ។

៣. ក្របខ័ណ្ឌច្បាប់ក្នុងប្រទេសយោងទៅនឹងកថាខ័ណ្ឌទី ២ (គ)ខាងលើត្រូវតែស្របទៅនឹងពិធីសារនេះ។

៤. ការខកខាននៃភាគីនាំចូលដើម្បីបញ្ជាក់ពីការទទួលបាននូវសេចក្តីជូនព័ត៌មាន មិនត្រូវឆ្លុះបញ្ចាំងពីការឯកភាពរបស់ភាគីនោះទៅនឹងចលនាឆ្លងដែនដោយចេតនាទេ។

## មាត្រា ១០

## នីតិវិធីធ្វើសេចក្តីសំរេច

១. រាល់សេចក្តីសំរេចទាំងឡាយ ដែលបានធ្វើឡើងដោយភាគីនាំចូលត្រូវអនុលោមទៅតាមមាត្រា ១៥។

២. ភាគីនាំចូលត្រូវជូនព័ត៌មានជាលាយលក្ខណ៍អក្សរដល់អ្នកជូនព័ត៌មាន (Notifier) ក្នុងរយៈពេលដែលមានចែងនៅក្នុងមាត្រា ៩ ថាតើចលនាឆ្លងដែនដោយចេតនាអាចដំណើរការបានដែរឬទេៈ

ក. បន្ទាប់ពីភាគីនាំចូល បានផ្តល់ការឯកភាពជាលាយលក្ខណ៍អក្សរ

ខ. បន្ទាប់ពីរយៈពេលមិនយឺតជាង ៩០ថ្ងៃ ដោយពុំមានការឯកភាពជាលាយលក្ខណ៍អក្សរ។

៣. នៅក្នុងរយៈពេល ២៧០ថ្ងៃ នៃកាលបរិច្ឆេទនៃការទទួលសេចក្តីជូនព័ត៌មាន ភាគីនាំចូលត្រូវទាក់ទងជាលាយលក្ខណ៍អក្សរទៅអ្នកជូនព័ត៌មាន និងទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព នូវសេចក្តីសំរេចយោងទៅលើកថាខ័ណ្ឌទី ២ ខាងលើចំពោះៈ

ក. ការអនុញ្ញាតឱ្យនាំចូលដោយមាន ឬគ្មានលក្ខខណ្ឌ រួមទាំងសេចក្តីសំរេចថាតើនឹងត្រូវអនុវត្តន៍ចំពោះការនាំចូលជាបន្តបន្ទាប់នៃសារពាង្គកាយកែច្នៃរស់ដូចគ្នាយ៉ាងដូចម្តេច? ។

ខ. ហាមឃាត់ការនាំចូល

គ. សំណើសុំព័ត៌មានពាក់ព័ន្ធបន្ថែម អនុលោមទៅតាមក្របខ័ណ្ឌច្បាប់ក្នុងប្រទេសរបស់ខ្លួន ឬឧបសម្ព័ន្ធទី ១ ។ក្នុងការគណនាពេលវេលាដែលភាគីនាំចូលនឹងត្រូវឆ្លើយតបទៅវិញចំនួនថ្ងៃដែលភាគីត្រូវរង់ចាំទទួលព័ត៌មាន បន្ថែមដែលទាក់ទងនោះ មិនត្រូវរាប់បញ្ចូលឡើយ ឬ

ឃ. ផ្តល់ព័ត៌មានដល់អ្នកជូនព័ត៌មានថា រយៈពេលដែលបានកំណត់នៅក្នុងកថាខ័ណ្ឌនេះ ត្រូវពន្យាពេលត្រឹមរយៈពេលកំណត់ច្បាស់លាស់។

៤. លើកលែងតែក្នុងករណីដែលមានការឯកភាពគ្មានលក្ខខណ្ឌ សេចក្តីសំរេចក្នុងកថាខ័ណ្ឌទី ៣ ខាងលើ ត្រូវបញ្ជាក់ពីហេតុផលដោយមានមូលដ្ឋានច្បាស់លាស់។

៥. ការខកខានដោយភាគីនាំចូលធ្វើទំនាក់ទំនងពីសេចក្តីសំរេចរបស់ខ្លួនក្នុងរយៈពេល ២៧០ ថ្ងៃ នៃកាលបរិច្ឆេទនៃការទទួលសេចក្តីបញ្ជាក់នោះ មិនត្រូវឆ្លុះបញ្ចាំងពីការឯកភាពទៅនឹងចលនាឆ្លងដែនដោយចេតនានោះទេ។

៦. ការខ្វះភាពច្បាស់លាស់ខាងវិទ្យាសាស្ត្រ ដោយសារតែព័ត៌មាន និងចំណេះដឹងវិទ្យាសាស្ត្រពាក់ព័ន្ធមិនគ្រប់គ្រាន់ទាក់ទងទៅនឹងវិសាលភាព នៃឥទ្ធិពលអវិជ្ជមានរបស់សារពាង្គកាយកែច្នៃរស់មកលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះក្នុងប្រទេសភាគីនាំចូល ដោយគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងនោះ មិនត្រូវរារាំងភាគីនោះក្នុងការធ្វើសេចក្តីសំរេចសមស្របមួយចំពោះការនាំចូលនៃសារពាង្គកាយកែច្នៃរស់ ដែលជាបញ្ហាដូចបានកំណត់ក្នុងកថាខ័ណ្ឌទី៣ ខាងលើ ដើម្បីជៀសវាង ឬកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមាន។

៧.សន្និសីទភាគីបំរើឱ្យកិច្ចប្រជុំរវាងភាគីទាំងអស់នៅក្នុងកិច្ចប្រជុំដំបូង ត្រូវសំរេចលើនីតិវិធី និងយន្តការដែលសមស្រប ដើម្បីជួយសំរបសំរួលការធ្វើសេចក្តីសំរេចដោយភាគីនាំចូល។

## មាត្រា ១១

## នីតិវិធីនៃសារពាង្គកាយកែច្នៃរស់ដែលត្រូវបានប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ

១. ភាគីដែលធ្វើសេចក្តីសំរេចចុងក្រោយលើការប្រើប្រាស់ក្នុងស្រុក រួមទាំងការដាក់លក់ នៅលើទីផ្សារនូវសារពាង្គកាយកែច្នៃរស់ ដែលអាចពាក់ព័ន្ធនឹងចលនាឆ្លងដែនសំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ត្រូវជូនព័ត៌មានដល់ភាគីទាំងអស់ តាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព ក្នុងរយៈពេល ១៥ថ្ងៃនៃការធ្វើសេចក្តីសំរេចនោះ។ ព័ត៌មាននេះយ៉ាងហោចណាស់ត្រូវមានព័ត៌មាន ដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២។ ភាគីនោះត្រូវផ្តល់ឯកសារចំលងជាលាយលក្ខណ៍អក្សរ ទៅស្ថាប័នបង្គោលជាតិរបស់ភាគីនីមួយៗ ដែលផ្តល់ព័ត៌មានដល់លេខាធិការដ្ឋានជាមុនថា ខ្លួនពុំអាចទំនាក់ទំនងទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពបានឡើយ។ "បទប្បញ្ញត្តិ" នេះនឹងមិនអនុវត្តន៍ ចំពោះសេចក្តីសំរេចណាដែលទាក់ទងទៅនឹងការប្តឹងឡើយ។

២. ភាគីដែលធ្វើសេចក្តីសំរេចទាក់ទងនឹងកថាខ័ណ្ឌទី ១ ខាងលើ ត្រូវធានាថាមានតំរូវការផ្លូវច្បាប់មួយសំរាប់ធានាភាពត្រឹមត្រូវនៃព័ត៌មានដែលបានផ្តល់ដោយអ្នកស្នើសុំ។

៣. ភាគីណាក៏ដោយអាចស្នើសុំព័ត៌មានបន្ថែមពីអាជ្ញាធរដូចដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ(ខ)ក្នុងឧបសម្ព័ន្ធទី ២។

៤. ភាគីណាក៏ដោយអាចធ្វើសេចក្តីសំរេចលើការនាំចូលសារពាង្គកាយកែច្នៃរស់ សំរាប់ប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬ សំរាប់ការកែច្នៃ នៅក្រោមក្របខ័ណ្ឌច្បាប់ក្នុងស្រុកដែលស្របទៅនឹងគោលបំណងរបស់ពិធីសារនេះ។

៥. ភាគីនីមួយៗត្រូវផ្តល់ឱ្យបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព នូវឯកសារចំលងនៃច្បាប់បរិធានជាតិ និងគោលការណ៍ណែនាំទាំងឡាយ ដែលអាចអនុវត្តន៍ចំពោះចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ។

៦. ភាគីប្រទេសកំពុងអភិវឌ្ឍន៍ ឬភាគីដែលមានវិស័យសេដ្ឋកិច្ចអន្តរកាល ដោយគ្មានក្របខ័ណ្ឌច្បាប់ក្នុងស្រុកស្របទៅនឹងកថាខ័ណ្ឌទី ៤ ខាងលើ និងដោយស្ថិតនៅក្រោមការអនុវត្តនៃដែនយុត្តាធិការរបស់ខ្លួន អាចប្រកាសតាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព នូវសេចក្តីសំរេចរបស់ខ្លួន មុនការនាំចូលលើកដំបូងនៃសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ដែលព័ត៌មាននេះត្រូវបានផ្តល់អោយនៅក្នុងកថាខ័ណ្ឌ ១ ខាងលើនឹងត្រូវបានរៀបចំដោយផ្អែកលើៈ

ក. ការវាយតំលៃហានិភ័យ ដែលអនុវត្តន៍ដោយយោងទៅលើឧបសម្ព័ន្ធទី ៣ និង

ខ. សេចក្តីសំរេចធ្វើឡើងនៅក្នុងពេលវេលាកំណត់មិនលើសពី ២៧០ ថ្ងៃ។

៧. ការខកខានដោយភាគីមិនបានផ្តល់ព័ត៌មាន ស្តីពីសេចក្តីសំរេចរបស់ខ្លួនទៅតាមកថាខ័ណ្ឌទី ៦ ខាងលើ មិនត្រូវបញ្ជាក់ពីការឯកភាព ឬការបដិសេធរបស់ខ្លួនចំពោះការនាំចូលនៃសារពាង្គកាយកែច្នៃរស់នោះទេ ទោះបីការនាំចូលនោះ មានបំណងសំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារចំណីសត្វឬសំរាប់ការកែច្នៃ បើមិនដូច្នេះទេត្រូវមានការបញ្ជាក់ ច្បាស់លាស់ដោយ ភាគីនាំចូលនោះ។

៨. ការខ្វះភាពច្បាស់លាស់ខាងវិទ្យាសាស្ត្រដោយសារតែចំណេះដឹងនិងព័ត៌មានវិទ្យាសាស្ត្រពាក់ព័ន្ធមិនគ្រប់ គ្រាន់ទាក់ទងទៅនឹងវិសាលភាពនៃឥទ្ធិពលអវិជ្ជមានរបស់សារពាង្គកាយកែច្នៃរស់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះនៅក្នុងប្រទេសជាភាគីនាំចូល ដោយគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ មិនត្រូវរារាំងដល់ភាគី នោះក្នុងការធ្វើសេចក្តីសំរេចសមស្របមួយលើការនាំចូលនៃសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារចំណីសត្វ ឬសំរាប់ការកែច្នៃ ដើម្បីជៀសវាង ឬកាត់បន្ថយឱ្យបានអប្បបរមានូវផលប៉ះពាល់អវិជ្ជមាននោះ។

៩. ភាគីណាក៏ដោយ អាចបង្ហាញនូវតំរូវការជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស និងការកសាងសមត្ថភាព ស្តីពីសារពាង្គកាយកែច្នៃរស់សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារចំណីសត្វឬសំរាប់ការកែច្នៃ ។ ភាគីទាំងអស់ត្រូវ សហប្រតិបត្តិការ គ្នាដើម្បីឆ្លើយតបទៅនឹងតំរូវការទាំងនេះ ដោយយោងទៅលើមាត្រា ២២ និង២៨។

## មាត្រា ១២
## ការពិនិត្យសេចក្តីសំរេចឡើងវិញ

១. នៅពេលណាក៏ដោយភាគីនាំចូល បានព័ត៌មានថ្មីអំពីផលប៉ះពាល់អវិជ្ជមានលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ និងដោយគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងនោះ អាចពិនិត្យកែសំរួល និងធ្វើការផ្លាស់ប្តូរសេចក្តីសំរេចទាក់ទងនឹងចលនាឆ្លងដែនដោយចេតនានេះ។ ករណីបែបនេះ ក្នុងរយៈពេល ៣០ ថ្ងៃ ភាគីនោះ ត្រូវផ្តល់ព័ត៌មាន

ទៅអ្នកជូនព័ត៌មានដែលបានបញ្ជាក់ពីលើកមុន លើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់នូវសេចក្តីសំរេចនេះ ព្រមទាំងបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពផងដែរ ហើយនឹងបង្ហាញពីហេតុផលនៃសេចក្តីសំរេចនេះ។

២. ភាគីនាំចេញ ឬអ្នកជូនព័ត៌មាន អាចស្នើសុំអោយភាគីនាំចូលធ្វើការពិនិត្យ កែសំរួលសេចក្តីសំរេចដែលបានធ្វើរួចហើយ ដោយអនុលោមទៅតាមមាត្រា ១០ ដែលភាគីនាំចេញ ឬអ្នកជូនព័ត៌មានពិចារណាថាៈ

ក. ការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈដែលបានកើតឡើងនោះ អាចជះឥទ្ធិពលដល់លទ្ធផលនៃការវាយតំលៃហានិភ័យ ដែលសេចក្តីសំរេចខាងលើនោះផ្អែកលើមូលដ្ឋាន ឬ

ខ. ព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេសពាក់ព័ន្ធបន្ថែមនោះអាចយកមកប្រើការបាន។

៣. ភាគីនាំចូល ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះសំណើបែបនោះនៅក្នុងរយៈពេល ៩០ ថ្ងៃ និងបញ្ជាក់ពីហេតុផលចំពោះសេចក្តីសំរេចរបស់ខ្លួន។

៤. ភាគីនាំចូលដោយមានការទទួលខុសត្រូវយ៉ាងប្រុងប្រយ័ត្នអាចទាមទារអោយធ្វើការវាយតំលៃពីហានិភ័យចំពោះការនាំចូលក្រោយៗទៀត។

## មាត្រា ១៣

## សំរួលនីតិវិធីឱ្យសាមញ្ញ

១. ដោយមានតែវិធានការណ៍សមស្របត្រូវបានអនុវត្តន៍ ដើម្បីធានានូវសុវត្ថិភាពនៃចលនាឆ្លងដែនចេតនានៃសារពាង្គកាយកែច្នៃរស់អនុលោមទៅតាមគោលបំណងនៃពិធីសារនេះ ភាគីនាំចូលអាចជូនព័ត៌មានជាមុនទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពៈ

ក. ករណីដែលក្នុងនោះចលនាឆ្លងដែនដោយចេតនាទៅភាគីនោះ អាចកើតឡើងស្របពេលដែលចលនានេះត្រូវបានជូនព័ត៌មានទៅភាគីនាំចូលនោះ និង

ខ.ការនាំចូលនៃសារពាង្គកាយកែច្នៃរស់ទៅភាគីនោះត្រូវបានលើកលែងពីនីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុន។

ការជូនព័តមាននៅក្នុងអនុកថាខ័ណ្ឌ"ក "ខាងលើអាចប្រើចំពោះសកម្មភាពដូចគ្នាក្រោយទៀតទៅលើភាគីដដែល។

២. ព័ត៌មាន ដែលទាក់ទងទៅនឹងចលនាឆ្លងដែនដោយចេតនា ដែលនឹងត្រូវផ្តល់អោយក្នុងការជូនព័ត៌មានយោងទៅនឹងកថាខ័ណ្ឌទី ១ ខាងលើ ត្រូវតែជាព័ត៌មានដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី ១។

## មាត្រា ១៤

## ការចាត់ចែង និងកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគី

១. ភាគីទាំងអស់អាចចុះកិច្ចព្រមព្រៀងពហុភាគី តំបន់ និង ទ្វេរភាគី និងការរៀបចំចាត់ចែងទាក់ទងទៅនឹងចលនាឆ្លងដែនចេតនានៃសារពាង្គកាយកែច្នៃរស់ ស្របទៅនឹងគោលបំណងនៃពិធីសារនេះ និងកិច្ចព្រមព្រៀង និងការរៀបចំចាត់ចែង ដែលមិនបណ្តាលអោយកំរិតនៃការការពារទាបជាងកំរិតការពារដែលផ្តល់ដោយពិធីសារនេះ។

២. ភាគីទាំងអស់ត្រូវផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក តាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពនូវរាល់កិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគ និងការរៀបចំចាត់ចែង ដែលភាគីនោះបានធ្វើមុន ឬក្រោយពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់ពិធីសារនេះ។

៣. "បទប្បញ្ញត្តិ" នៃពិធីសារនេះ នឹងមិនប៉ះពាល់ដល់ចលនាឆ្លងដែនចេតនា ដោយអនុលោមទៅតាមកិច្ចព្រមព្រៀង និងការរៀបចំចាត់ចែងដែលធ្វើឡើងរវាងភាគីនៃកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទាំងនោះទេ។

៤. ភាគីទាំងឡាយ អាចកំណត់ថាច្បាប់ប្រទេសរបស់ខ្លួន ត្រូវអនុវត្តន៍ដោយអនុលោមទៅតាមការនាំចូលដាក់ស្តែងទៅក្នុងប្រទេសនោះ ហើយត្រូវជូនព័ត៌មានទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព អំពីសេចក្តីសំរេចរបស់ខ្លួន។

## មាត្រា ១៥

## ការវាយតំលៃពីហានិភ័យ

១. ការវាយតំលៃហានិភ័យ ដែលបានអនុវត្តន៍ដោយអនុលោមទៅតាមពិធីសារនេះ ត្រូវរៀបចំធ្វើឡើងក្នុងគោលដៅវិទ្យាសាស្ត្រ ដោយអនុលោមតាមឧបសម្ព័ន្ធទី ៣ និងត្រូវគិតគូរពីបច្ចេកទេសវាយតំលៃហានិភ័យ។ ការវាយតំលៃហានិភ័យបែបនេះ ត្រូវផ្អែកលើព័ត៌មានដែលបានចែងនៅក្នុងមាត្រា ៨ និងភស្តុតាងវិទ្យាសាស្ត្រដែលអាចយក ជាការ បានផ្សេងទៀត ដើម្បីវាយតំលៃពីផលប៉ះពាល់អវិជ្ជមាននៃសារពាង្គកាយរស់ដែលកែច្នៃរស់ ទៅលើការអភិរក្សនិងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ព្រមទាំងគិតគូរពីហានិភ័យទៅលើសុខភាពមនុស្សផងដែរ។

២. ភាគីនាំចូលត្រូវធានាថា ការវាយតំលៃហានិភ័យត្រូវបានអនុវត្តន៍ចំពោះសេចក្តីសំរេច នៅក្នុងមាត្រា ១០។ ភាគីនេះអាចទាមទារអោយអ្នកនាំចេញអនុវត្តន៍នូវការវាយតំលៃហានិភ័យនេះ។

៣. ការចំណាយនៃការវាយតំលៃហានិភ័យ ត្រូវចេញដោយអ្នកជូនព័ត៌មានប្រសិនបើភាគីនាំចូលទាមទារដូច្នេះ។

## មាត្រា ១៦

## ការគ្រប់គ្រងហានិភ័យ

១. ភាគីទាំងអស់ ដោយផ្អែកលើមាត្រា ៨ (g) នៃអនុសញ្ញានេះ ត្រូវបង្កើត និងរក្សានូវយន្តការ វិធានការណ៍ និងយុទ្ធសាស្ត្រសមស្រប ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យ ហានិភ័យដែលបានកំណត់នៅក្នុង "បទប្បញ្ញត្តិ នៃការវាយតំលៃហានិភ័យរបស់ពិធីសារនេះ ទាក់ទងនឹងការប្រើប្រាស់ ការគ្រប់គ្រង និងចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់។

២. វិធានការណ៍ផ្អែកលើការវាយតំលៃហានិភ័យត្រូវបានដាក់កំហិតដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃសារពាង្គកាយកែច្នៃរស់ ទៅលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តភាពនៃជីវៈចម្រុះ ដោយគិតគូរផងដែរពីហានិភ័យទៅលើសុខភាពមនុស្សនៅក្នុងទឹកដីនៃភាគីនាំចូល។

៣. ភាគីនីមួយៗត្រូវចាត់វិធានការណ៍អោយបានសមស្របដើម្បីទប់ស្កាត់សកម្មភាពឆ្លងដែនអចេតនា នៃសារពាង្គកាយកែច្នៃរស់ រួមទាំងវិធានការណ៍តំរូវអោយមានការវាយតំលៃហានិភ័យ ដែលនឹងត្រូវអនុវត្តន៍ឱ្យបានមុនអនុញ្ញាតឱ្យបញ្ចេញលើកដំបូង នូវសារពាង្គកាយកែច្នៃរស់។

៤. ដោយមិនពាក់ព័ន្ធទៅនឹងកថាខ័ណ្ឌទី ២ ខាងលើ ភាគីនីមួយៗ ត្រូវខិតខំខ្នែងដើម្បីធានាថាសារពាង្គកាយកែច្នៃរស់ ទោះជាត្រូវបាននាំចូល ឬអភិវឌ្ឍន៍ក្នុងស្រុកក៏ដោយ បានដាក់ឱ្យឆ្លងកាត់រយៈពេលនៃការត្រួតពិនិត្យយ៉ាងហ្មត់ចត់ដែលស្មើគ្នាទៅនឹងវដ្តនៃជីវិត ឬរយៈពេលនៃការផលិត មុនពេលដាក់ឱ្យប្រើប្រាស់។

៥. ភាគីទាំងឡាយត្រូវសហប្រតិបត្តិការដើម្បីៈ

ក. កំណត់សារពាង្គកាយកែច្នៃរស់ ឬកំណត់លក្ខណៈពិសេសនៃសារពាង្គកាយកែច្នៃរស់ ដែលអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ព្រមទាំងគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ។

ខ. ចាត់វិធានការណ៍អោយបានសមស្រប ដែលទាក់ទងទៅនឹងការថែរក្សានៃសារពាង្គកាយកែច្នៃរស់ ឬលក្ខណៈពិសេសរបស់វា។

## មាត្រា ១៧

## ចលនាឆ្លងដែនអចេតនា និងវិធានការណ៍បន្ទាន់

១. ភាគីនីមួយៗ ត្រូវចាត់វិធានការណ៍អោយបានសមស្រប ដើម្បីជូនព័ត៌មានដល់ប្រទេសរងគ្រោះ និងប្រទេសទទួលរងគ្រោះខ្លាំង បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព និងអង្គការអន្តជាតិដែលពាក់ព័ន្ធ នៅពេលទទួលដំណឹងពីការកើតឡើងក្នុងដែនយុត្តាធិការរបស់ខ្លួន ដែលនាំឱ្យ ឬអាចនាំអោយមានចលនាឆ្លងដែនដោយអចេតនានៃសារពាង្គកាយកែច្នៃរស់ ដែលទំនងជាមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ព្រមទាំងគិតគូរពីហានិភ័យដល់សុខភាពមនុស្សនៃប្រទេសនោះផងដែរ។

២. ភាគីនីមួយៗ ត្រូវជូនព័ត៌មានទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព មិនយឺតជាងកាលបរិច្ឆេទនៃការចូលជាធរមាននៃភាគីនោះក្នុងពិធីសារនេះ នូវព័ត៌មានលំអិតដែលពាក់ព័ន្ធនឹងអាស័យដ្ឋានទំនាក់ទំនងដើម្បីទទួលព័ត៌មានដែលមានចែងក្នុងមាត្រានេះ។

៣. ព័ត៌មានទាំងឡាយ ដែលមាននៅក្នុងកថាខ័ណ្ឌទី ១ ខាងលើនេះរួមបញ្ចូលៈ

ក. ព័ត៌មានទាក់ទងដែលអាចទទួលបាន ស្តីពីបរិមាណវាយតំលៃប្រហែល និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយកែច្នៃរស់។

ខ. ព័ត៌មានស្តីពីកាលៈទេសៈ និងកាលបរិច្ឆេទសំរាប់ការបញ្ចេញ និងការប្រើប្រាស់នៃសារពាង្គកាយកែច្នៃរស់នៅក្នុងភាគីជាដើមកំណើតនៃសារពាង្គកាយនោះ។

គ. ព័ត៌មានដែលអាចទទួលបាន អំពីផលប៉ះពាល់អវិជ្ជមានលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ និងគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ ព្រមទាំងព័ត៌មានស្តីពីវិធានការណ៍គ្រប់គ្រងហានិភ័យដែលអាចកើតមានឡើង។

ឃ. ព័ត៌មានពាក់ព័ន្ធផ្សេងទៀត និង

ង. អាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែម។

៤. ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ធ្ងន់ធ្ងរលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តភាពនៃជីវចម្រុះ ដោយគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ ភាគីនីមួយៗដែលនៅក្នុងដែនយុត្តាធិការរបស់ខ្លួន នៅពេលបញ្ចេញនូវសារពាង្គកាយកែច្នៃរស់យោងទៅលើកថាខ័ណ្ឌទី ១ ខាងលើ កើតមានឡើងត្រូវពិគ្រោះយោបល់ជាបន្ទាន់ជាមួយប្រទេសដែលទទួលរងនូវការប៉ះពាល់ ឬប្រទេសដែលទទួលរងនូវការប៉ះពាល់ខ្លាំង ដើម្បីជំរុញឱ្យភាគីទាំងនោះធ្វើការកំណត់នូវដំណោះស្រាយ និងផ្តួចផ្តើមសកម្មភាពចាំបាច់រួមទាំងវិធានការណ៍បន្ទាន់។

## មាត្រា ១៨

## ការគ្រប់គ្រង ការដឹកជញ្ជូន ការវិចខ្ចប់ និងអត្តសញ្ញាណកម្ម

១. ដើម្បីចៀសវាងផលប៉ះពាល់ផ្សេងៗទៅលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ដោយគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ ភាគីនីមួយៗត្រូវចាត់វិធានការណ៍ចាំបាច់ដើម្បីតំរូវឱ្យសារពាង្គកាយកែច្នៃរស់ ដែលជាកម្មវត្ថុនៃចលនាឆ្លងដែនដោយចេតនានៅក្នុងវិសាលភាពនៃពិធីសារនេះគឺ ត្រូវបានគ្រប់គ្រង វេចខ្ចប់ និងដឹកជញ្ជូនដោយសុវត្ថិភាពដោយគិតគូរទៅលើច្បាប់ និងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ។

២. ភាគីនីមួយៗត្រូវចាត់វិធានការណ៍ផ្សេងៗ ដើម្បីតំរូវអោយមានឯកសារស្តីពីៈ

ក. សារពាង្គកាយកែច្នៃរស់ដែលសំរាប់ប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ត្រូវកំណត់ឱ្យច្បាស់ថាសារពាង្គកាយទាំងនោះអាចផ្ទុកសារពាង្គកាយកែច្នៃរស់ និងមិនត្រូវបានអោយនាំចូលដោយចេតនាទៅក្នុងបរិស្ថាន ព្រមទាំងបញ្ជាក់ឱ្យច្បាស់ពីអាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែម។ សន្និសីទភាគី បំរើជាកិច្ចប្រជុំរវាងភាគីចុះកិច្ចសន្យា ទៅនឹងពិធីសារនេះ ត្រូវធ្វើសេចក្តីសំរេចទៅលើតំរូវការលំអិតសំរាប់ គោលបំណងនេះរួមទាំងការបញ្ជាក់យ៉ាងច្បាស់ពីអត្តភាព និងអត្តភាពប្លែកៗ របស់សារពាង្គកាយទាំងនេះ មិនយឺតជាង ២ ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានទៅក្នុងពិធីសារនេះ។

ខ. សារពាង្គកាយកែច្នៃរស់ដែលមានទិសដៅសំរាប់ការប្រើប្រាស់ដោយមានកំរិត ត្រូវកំណត់អោយបានច្បាស់លាស់ថា វាពិតជាសារពាង្គកាយកែច្នៃរស់ និងត្រូវបញ្ជាក់ពីតំរូវការផ្សេងៗសំរាប់ការគ្រប់គ្រង ការផ្ទុក ការដឹកជញ្ជូន និងការប្រើប្រាស់ដោយសុវត្ថិភាព រួមទាំងអាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែមនៃបុគ្គល និងស្ថាប័នដែលទទួលខុសត្រូវ លើបញ្ហាសារពាង្គកាយកែច្នៃរស់នេះ។

គ. សារពាង្គកាយកែច្នៃរស់ ដែលត្រូវបានគេគ្រោងទុកសំរាប់នាំចូលដោយចេតនាទៅក្នុងបរិស្ថាន នៃភាគីនាំចូល និងសារពាង្គកាយកែច្នៃរស់ផ្សេងទៀតនៅក្នុងវិសាលភាពនៃពិធីសារនេះត្រូវធ្វើអត្តសញ្ញាណកម្មអោយបានច្បាស់លាស់ ក្នុងនាមជាសារពាង្គកាយកែច្នៃរស់ ត្រូវបញ្ជាក់ពីអត្តភាព និងបុគ្គលិកលក្ខណៈពិសេសៗ តំរូវការនានាសំរាប់ការគ្រប់គ្រង ការផ្ទុក ការដឹកជញ្ជូន និងការប្រើប្រាស់ដោយសុវត្ថិភាព អាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែម និងឈ្មោះ, អាស័យដ្ឋាន នៃអ្នកនាំចេញ និងអ្នកនាំចូល ដោយមានការបញ្ជាក់ ពីចលនានេះគឺស្របទៅនឹងតំរូវការនៃពិធីសារនេះដែលអនុវត្តន៍ចំពោះអ្នកនាំចេញ។

៣. សន្និសីទភាគីបំរើជាកិច្ចប្រជុំរវាងភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវពិចារណាដល់សេចក្តីត្រូវការ និងគំរូនៃបទដ្ឋានទាក់ទងនឹងការធ្វើអត្តសញ្ញាណកម្ម ការគ្រប់គ្រង ការវិចខ្ចប់ និងការដឹកជញ្ជូន ដោយធ្វើការពិគ្រោះយោបល់ ជាមួយនឹងអង្គការអន្តរជាតិពាក់ព័ន្ធ។

## មាត្រា ១៩

## អាជ្ញាធរសមត្ថកិច្ចជាតិ និងស្ថាប័នបង្គោលជាតិ

១. ភាគីនីមួយៗ ត្រូវតែងតាំងបុគ្គលបង្គោលជាតិមួយរូប(National Focal Point) ដែលទទួលខុសត្រូវការងារទំនាក់ទំនងជាមួយលេខាធិការដ្ឋានជួសមុខឱ្យភាគីរបស់ខ្លួន។ ភាគីនីមួយៗ ត្រូវតែងតាំងផងដែរនូវអាជ្ញាធរសមត្ថកិច្ចជាតិមួយ ឬច្រើនដែលទទួលខុសត្រូវក្នុងមុខងាររដ្ឋបាលដែលកំណត់ដោយពិធីសារនេះ និងដែលមានអំណាចជំនួសមុខឱ្យភាគីរបស់

ខ្លួន ដោយគោរពទៅតាមមុខងារទាំងនោះ។ ភាគីអាចតែងតាំងអង្គភាពតែមួយ ដើម្បីបំពេញមុខងារទាំងបុគ្គលបង្គោល និងអាជ្ញាធរសមត្ថកិច្ចជាតិ។

២. ភាគីនីមួយៗ ត្រូវជូនដំណឹងទៅលេខាធិការដ្ឋាននូវឈ្មោះ និងអាស័យដ្ឋានរបស់បុគ្គលបង្គោល និងអាជ្ញាធរសមត្ថកិច្ចជាតិ មិនអោយហួសពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះទេ។ ភាគីដែលតែងតាំងអាជ្ញាធរសមត្ថកិច្ចជាតិលើសពីមួយ ភាគីនោះត្រូវបង្ហាញដល់លេខាធិការដ្ឋាននូវព័ត៌មានដែលទាក់ទងទៅនឹងការទទួលខុសត្រូវនៃអាជ្ញាធរទាំងនោះ។ នៅទីណាដែលអាចអនុវត្តន៍បានយ៉ាងហោចណាស់ព័ត៌មានបែបនេះគឺត្រូវបញ្ជាក់ពីការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចចំពោះប្រភេទនៃសារពាង្គកាយកែច្នៃរស់។ ភាគីនីមួយៗត្រូវបញ្ជូនដំណឹងភ្លាមដល់លេខាធិការដ្ឋាននូវការផ្លាស់ប្តូរក្នុងការតែងតាំងបុគ្គលបង្គោលជាតិ ឬឈ្មោះ និងអាស័យដ្ឋាន ឬការទទួលខុសត្រូវរបស់អាជ្ញាធរសមត្ថកិច្ចជាតិ។

៣. លេខាធិការដ្ឋាន ត្រូវផ្តល់ព័ត៌មាននិងជូនដំណឹងជាបន្ទាន់ទៅភាគីទាំងឡាយ នូវព័ត៌មានដែលគេទទួលបានដូចមានចែងក្នុងកថាខ័ណ្ឌទី ២ ខាងលើ ព្រមទាំងផ្តល់ព័ត៌មានបែបនេះទៅបណ្តាញផ្សព្វផ្សាយព័តមានជីវសុវត្ថិភាព។

## មាត្រា ២០

## ការចែកចាយព័ត៌មាន និងបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព

១. បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃយន្តការផ្សព្វផ្សាយព័ត៌មានក្នុងមាត្រា ១៨ កថាខ័ណ្ឌទី ៣ នៃអនុសញ្ញានេះដើម្បី:

ក. ជួយសម្រួលការដោះដូរព័ត៌មានវិទ្យាសាស្ត្រ បច្ចេកទេស បរិស្ថាន និងច្បាប់ និងបទពិសោធន៍ ស្តីពីសារពាង្គកាយកែច្នៃរស់។

ខ. ជួយដល់ភាគីក្នុងការអនុវត្តពិធីសារនេះ ដោយគិតគូរដល់តំរូវការពិសេសនៃភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ជាកោះតូចៗ និងប្រទេសមានសេដ្ឋកិច្ចអន្តរកាល ក៏ដូចជាប្រទេសដែលជាប្រភពដើម និងជាមណ្ឌលប្រមូលផ្តុំសេនេទិចចម្រុះ។

២. បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព ត្រូវបំរើជាមធ្យោបាយក្នុងការផ្តល់ព័ត៌មានដែលការផ្តល់ព័តមាននោះអាចធ្វើឡើងបាន សំរាប់គោលបំណងនៃកថាខ័ណ្ឌទី ១ ខាងលើ។ បណ្តាញផ្សព្វផ្សាយព័ត៌មាននឹងផ្តល់ព័ត៌មានយ៉ាងទូលាយដល់ភាគីពាក់ព័ន្ធ នឹងការអនុវត្តពិធីសារនេះ។ វាក៏ផ្តល់ផងដែរនូវយន្តការក្នុងការផ្លាស់ប្តូរ ព័ត៌មានជីវសុត្ថិភាពអន្តរជាតិផ្សេងទៀត។

៣. ដោយពុំមានការទាក់ទងទៅនឹងកិច្ចការពារនៃព័ត៌មានសម្ងាត់ ភាគីនីមួយៗត្រូវផ្តល់ព័ត៌មានទៅឱ្យបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព នូវព័ត៌មានណាដែលចាំបាច់សំរាប់បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពនៅក្នុងពិធីសារនេះ ព្រមទាំង:

ក. ច្បាប់ បទដ្ឋាន គោលការណ៍ណែនាំដែលមានស្រាប់ សំរាប់ការអនុវត្តពិធីសារនេះ ព្រមទាំងព័ត៌មានដែលជាតំរូវការដោយភាគីទាំងនោះ សំរាប់នីតិវិធីកិច្ចព្រមព្រៀងជូនព័ត៌មានជាមុន។

ខ. កិច្ចព្រមព្រៀង និងការរៀបចំចាត់ចែងពហុភាគីតំបន់ និងទ្វេភាគី

គ. សេចក្តីសង្ខេបនៃការវាយតំលៃពីហានិភ័យ ឬការពិនិត្យមើលពីបរិស្ថាននៃសារពាង្គកាយកែច្នៃរស់ ដែលអនុវត្តន៍តាមដំណើរការនៃបទបញ្ញត្តិរបស់ខ្លួន និងអនុវត្តន៍ដោយយោងទៅលើមាត្រា ១៥ រួមមាន

ព័ត៌មានពាក់ព័ន្ធស្តីពី ផលិតផលជាសារធាតុកែច្នៃ ដែលមានប្រភពដើមជាសារពាង្គកាយកែច្នៃរស់ផ្ទុកនូវសារធាតុផ្សំរកឃើញថ្មី នៃសំភារៈសេនេទិចដែលទទួលបានពីការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប។

ឃ. សេចក្តីសំរេចចុងក្រោយទាក់ទងនឹងការនាំចេញ និងការបញ្ចេញនូវសារពាង្គកាយកែច្នៃរស់។

ង. របាយការណ៍ដែលត្រូវបានផ្តល់ឱ្យដោយយោងទៅតាមមាត្រា ៣៣ រួមបញ្ចូលរបាយការណ៍ ស្តីពីការអនុវត្តនីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុន។

៤. គំរូនៃការប្រតិបត្តិរបស់បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព រួមបញ្ចូលរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួនត្រូវតែយកមកពិចារណា និងសំរេចដោយយោលទៅលើសន្និសីទភាគី ដែលជាកិច្ចប្រជុំរវាងភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះនៅក្នុងកិច្ចប្រជុំដំបូង ហើយត្រូវបានបន្តត្រួតពិនិត្យឡើងវិញបន្ទាប់ពីនោះ។

## មាត្រា ២១
## ព័ត៌មានសម្ងាត់

១. ភាគីនាំចូល ត្រូវអនុញ្ញាតអោយអ្នកជូនព័ត៌មាន ដើម្បីកំណត់នូវព័ត៌មានដែលផ្តល់ជូន នៅក្រោមនីតិវិធីនៃពិធីសារនេះ ឬត្រូវការដោយភាគីនាំចូលជាផ្នែកមួយនៃនីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុនរបស់ពិធីសារ ដែលត្រូវរក្សាឱ្យបានសម្ងាត់ ។ ការបញ្ជាក់ពីហេតុផលត្រូវផ្តល់ជូនក្នុងករណីនោះ ប្រសិនបើមានសំណើ។

២. ភាគីនាំចូល ត្រូវពិគ្រោះយោបល់ជាមួយអ្នកជូនព័ត៌មាន ប្រសិនបើភាគីនោះសំរេចថាព័ត៌មានដែលកំណត់ដោយអ្នកជូនព័ត៌មានជាឯកសារសម្ងាត់ លាក់ការ គឺមិនមានលក្ខណៈជាឯកសារលាក់ការ ហើយភាគីនោះត្រូវផ្តល់ដំណឹងដល់អ្នកជូនព័ត៌មាននូវសេចក្តីសំរេចរបស់ខ្លួន មុនធ្វើការផ្សព្វផ្សាយដោយផ្តល់នូវហេតុផលទៅលើសំណើ ព្រមទាំងឱកាសសំរាប់ពិគ្រោះយោបល់ និងពិនិត្យឡើងវិញនូវសេចក្តីសំរេចមុននឹងធ្វើការផ្សព្វផ្សាយ។

៣. ភាគីនីមួយៗ ត្រូវរក្សានូវព័ត៌មានលាក់ការដែលទទួលបាននៅក្នុងពិធីសារនេះ រួមបញ្ចូលព័ត៌មានលាក់ការដែលបានទទួលនៅក្នុងបរិបទនៃនីតិវិធីនៃកិច្ចព្រមព្រៀងជូនព័ត៌មានជាមុនរបស់ពិធីសារនេះ។
ភាគីនីមួយៗត្រូវធានាថាខ្លួនមាននីតិវិធីដើម្បីរក្សាព័ត៌មានបែបនោះ និងត្រូវការពារព័ត៌មានលាក់ការនេះក្នុងគោលបំណងរក្សាព័ត៌មានសម្ងាត់ទាក់ទងនឹង សារពាង្គកាយកែច្នៃរស់ក្នុងស្រុក។

៤. ភាគីនាំចូល មិនត្រូវប្រើប្រាស់ព័ត៌មាននោះសំរាប់គោលបំណងពាណិជ្ជកម្មទេ លើកលែងតែមានការឯកភាពជាលាយល័ក្ខអក្សរពីអ្នកជូនព័ត៌មាន។

៥. ប្រសិនបើអ្នកជូនព័ត៌មានដកចេញ ឬបានដកចេញនូវព័ត៌មាននេះ ភាគីនាំចូលត្រូវគោរពនូវការសម្ងាត់នៃព័ត៌មានពាណិជ្ជកម្ម និងឧស្សាហកម្ម រួមទាំងព័ត៌មាននៃការស្រាវជ្រាវ និងការអភិវឌ្ឍ ក៏ដូចជាព័ត៌មានដែលភាគីនោះ និងអ្នកជូនព័ត៌មានមិនយល់ស្របថាជាការសម្ងាត់របស់ខ្លួន។

៦. ដោយមិនទាក់ទងនឹងកថាខ័ណ្ឌទី៥ខាងលើនេះព័ត៌មានខាងក្រោមនេះមិនត្រូវបានចាត់ទុកជាព័ត៌មានលាក់ការទេៈ

ក. ឈ្មោះ និងអាស័យដ្ឋានអ្នកជូនព័ត៌មាន

ខ. ការពណ៌នាទូទៅលើសាពាង្គកាយរស់ និងសារពាង្គកាយកែច្នៃរស់

គ. សេចក្តីសង្ខេបនៃការវាយតំលៃហានិភ័យលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះដោយគិតគូរពីហានិភ័យដល់សុខភាពមនុស្សផងដែរ និង

ឃ. វិធីសាស្ត្រ និងផែនការសំរាប់ឆ្លើយតបនឹងគ្រោះអាសន្ន។

## មាត្រា ២២
## ការកសាងសមត្ថភាព

១. ភាគីដែលចុះកិច្ចសន្យា ត្រូវធ្វើសហប្រតិបត្តិការគ្នាក្នុងការអភិវឌ្ឍ និងពង្រឹងធនធានមនុស្ស និងសមត្ថភាពស្ថាប័នក្នុងវិស័យជីវសុវត្ថិភាព រួមទាំងជីវបច្ចេកវិទ្យាដែលត្រូវការសំរាប់ជីវសុវត្ថិភាព សំរាប់គោលបំណងនៃការអនុវត្តពិធីសារនេះអោយមានប្រសិទ្ធិភាព នៅក្នុងភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍតិចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ដែលជាកោះតូចៗ និងប្រទេសមានសេដ្ឋកិច្ចអន្តរកាលតាមរយៈស្ថាប័ន និងអង្គការថ្នាក់ពិភពលោក តំបន់ អនុតំបន់ និងជាតិ និងតាមរយៈការជួយសម្រួលការចូលរួមរបស់ផ្នែកឯកជន។

២. ចំពោះគោលបំណងនៃការអនុវត្តកថាខ័ណ្ឌទី ១ ខាងលើ ទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការតំរូវការ នៃភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍន៍តិចបំផុត ប្រទេសកំពុងអភិវឌ្ឍន៍ជាកោះតូចៗ និងប្រទេសមានសេដ្ឋកិច្ចអន្តរកាលចំពោះធនធានហិរញ្ញវត្ថុ និងសិទ្ធិប្រើប្រាស់និងការផ្ទេរបច្ចេកវិទ្យា និងវិធីសាស្ត្រយោងទៅនឹង "បទបញ្ញត្តិ " ពាក់ព័ន្ធទៅនឹងអនុសញ្ញានេះ ត្រូវគិតគូរអោយបានពេញលេញសំរាប់ការកសាងសមត្ថភាពខាងជីវសុវត្ថិភាព។ កិច្ចសប្រតិបត្តិការទាក់ទងទៅនឹងស្ថានភាពខុសៗគ្នា សមត្ថភាព និងតំរូវការនៃភាគីនីមួយៗ រួមបញ្ចូលការបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងបច្ចេកទេសលើការគ្រប់គ្រងជីវបច្ចេកវិទ្យាឱ្យសមស្រប និងមានសុវត្ថិភាព ព្រមទាំងការប្រើប្រាស់នៃការវាយតំលៃហានិភ័យ និងការគ្រប់គ្រងហានិភ័យសំរាប់ជីវសុវត្ថិភាព ហើយលើការបង្កើនសមត្ថភាពស្ថាប័ន និងបច្ចេកវិទ្យានៃជីវសុវត្ថិភាព។ តំរូវការនៃភាគីដែលមានសេដ្ឋកិច្ចអន្តរកាល ត្រូវគិតគូរយ៉ាងហ្មត់ចត់ចំពោះការកសាងសមត្ថភាពបែបនេះលើជីវសុវត្ថិភាព។

## មាត្រា ២៣
## ការចូលរួម និងការយល់ដឹងសាធារណៈ

១. ភាគីចុះកិច្ចសន្យាត្រូវៈ

ក. ជំរុញ និងជួយសម្រួលការចូលរួម ការអប់រំ ការយល់ដឹងសាធារណៈ ពាក់ព័ន្ធទៅនឹងការផ្ទេរ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសុវត្ថិភាពនូវសារពាង្គកាយកែច្នៃរស់ទាក់ទងទៅនឹងការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ហើយត្រូវគិតគូរផងដែរដល់ហានិភ័យនៃសុខភាពមនុស្ស។ ក្នុងអត្ថន័យនេះ ភាគីទាំងនេះត្រូវសហការឱ្យបាន សមស្របជាមួយប្រទេស និងអង្គការអន្តរជាតិផ្សេងទៀត។

ខ. ខំប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីធានាថាការអប់រំ និងការយល់ដឹងសាធារណៈគ្របដណ្តប់សិទ្ធប្រើប្រាស់ព័ត៌មានស្តីពីសារពាង្គកាយកែច្នៃរស់ ដែលបានធ្វើអត្តសញ្ញាណកម្មដោយយោលទៅតាមពិធីសារនេះ ដែលអាចអនុញ្ញាតឱ្យនាំចូល។

២. យោលទៅលើច្បាប់បរិធានរបស់ប្រទេសនីមួយៗ ភាគីចុះកិច្ចសន្យាត្រូវពិគ្រោះយោបល់សាធារណៈពីដំណើរការនៃការធ្វើសេចក្តីសំរេចដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ និងប្រកាសលទ្ធផលនៃសេចក្តីសំរេចនោះ ដល់សាធារណៈដោយគោរពទៅតាមព័ត៌មានលាក់ការដូចមានចែងក្នុងមាត្រា ២១។

៣. ភាគីនីមួយៗ ត្រូវខិតខំប្រឹងប្រែងជូនដំណឹងដល់សាធារណៈ អំពីមធ្យោបាយទូទៅដែលអាចទំនាក់ទំនងទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព។

## មាត្រា ២៤
## ភាគីដែលមិនទាន់ចុះកិច្ចសន្យា

១. ចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ រវាងភាគីចុះកិច្ចសន្យា និងភាគីមិនទាន់ចុះកិច្ចសន្យា ត្រូវគោរពទៅតាមគោលបំណងនៃពិធីសារនេះ។ ភាគីចុះកិច្ចសន្យានេះ អាចចុះកិច្ចព្រមព្រៀង និងកិច្ចរៀបចំចាត់ចែងពហុភាគី តំបន់ និងទ្វេភាគី ជាមួយនឹងភាគីមិនទាន់ចុះកិច្ចសន្យា អំពីចលនាឆ្លងដែន។

២. ភាគីចុះកិច្ចសន្យា ត្រូវជំរុញដល់ភាគីដែលមិនទាន់ចុះកិច្ចសន្យាអោយផ្តល់ការគាំទ្រចំពោះពិធីសារនេះ និងផ្តល់វិភាគទានព័ត៌មានសមស្រប ដល់បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពស្តីពីសារពាង្គកាយកែច្នៃរស់ ដែលត្រូវបានបញ្ចេញ ឬនាំចូលទៅក្នុង ឬនាំចេញទៅក្រៅតំបន់ ដែលស្ថិតនៅក្នុងដែនយុត្តាធិការជាតិរបស់ខ្លួន។

## មាត្រា ២៥
## ចលនាឆ្លងដែនខុសច្បាប់

១. ប្រសិនបើសមស្រប ភាគីនីមួយៗត្រូវអនុម័តវិធានការក្នុងស្រុកសមស្របដែលមានគោលដៅការពារ និងដាក់ពិន័យលើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ដែលអនុវត្តន៍ផ្ទុយទៅនឹងវិធានការក្នុងស្រុករបស់ខ្លួន។ ចលនាបែបនេះត្រូវបានចាត់ទុកថាជាចលនាឆ្លងដែនខុសច្បាប់។

២. ក្នុងករណីដែលមានចលនាឆ្លងដែនខុសច្បាប់ ភាគីទទួលផលប៉ះពាល់អាចស្នើសុំអោយភាគីនាំចូល បង់ថ្លៃខូចខាតទៅលើសារពាង្គកាយកែច្នៃរស់ ដោយចោទសួរពីការយកត្រលប់ទៅវិញ ឬបំផ្លាញចោលឱ្យបានសមស្រប។

៣. ភាគីនីមួយៗ ត្រូវផ្តល់ព័ត៌មានទាក់ទងទៅនឹងករណីនៃចលនាឆ្លងដែនខុសច្បាប់ ដល់បណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព ដែលពាក់ព័ន្ធនឹងខ្លួន។

## មាត្រា ២៦
## ការពិចារណាផ្នែកសេដ្ឋកិច្ចសង្គម

១. ភាគីចុះកិច្ចសន្យា មុននឹងឈានដល់សេចក្តីសំរេចលើការនាំចូលយោងលើពិធីសារ ឬវិធានការនៅក្នុងប្រទេសរបស់ខ្លួនដោយអនុវត្តន៍ពិធីសារនេះ អាចគិតគូរឱ្យបានសមស្របទៅតាមកាតព្វកិច្ចអន្តរជាតិ ការពិចារណាសេដ្ឋកិច្ចសង្គមបណ្តាលមកពីផលប៉ះពាល់នៃសារពាង្គកាយកែច្នៃរស់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះជាពិសេសពីតំលៃនៃជីវៈចម្រុះចំពោះហគមន៍មូលដ្ឋាន និងជនជាតិភាគតិច។

២. ភាគីចុះកិច្ចសន្យា ត្រូវលើកទឹកចិត្តអោយមានកិច្ចសហប្រតិបត្តិការលើការស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មានស្តីពីផលប៉ះពាល់នៃសារពាង្គកាយកែច្នៃរស់ លើសេដ្ឋកិច្ចសង្គម ជាពិសេសលើសហគមន៍មូលដ្ឋាន និងជនជាតិភាគតិច។

## មាត្រា ២៧

## ការទទួលខុសត្រូវ **ផ្នែក** ច្បាប់ និងសំណងការខូចខាត

សន្និសីទភាគីដែលបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវអនុម័តនៅក្នុងកិច្ចប្រជុំលើកដំបូងនូវដំណើរការមួយទាក់ទងទៅនឹងការពិពណ៌នានៃច្បាប់អន្តរជាតិ និងនីតិវិធីលើការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតដែលបណ្តាលមកពីចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ដោយធ្វើការវិភាគ និងគិតគូរពីដំណើរការកំពុងអនុវត្តន៍នៅក្នុងច្បាប់អន្តរជាតិស្តីពីបញ្ហាទាំងនោះ ហើយត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីសំរេចដំណើរការនេះ ក្នុងរយៈពេល ៤ ឆ្នាំ។

## មាត្រា ២៨

## ធនធាន និងយន្តការហិរញ្ញវត្ថុ

១. ដោយគិតគូរពីធនធានហិរញ្ញវត្ថុ សំរាប់ការអនុវត្តពិធីសារនេះ ភាគីចុះកិច្ចសន្យាត្រូវគិតគូរពី "បទបញ្ញត្តិ" ដែលមានចែងនៅក្នុងមាត្រា ២០ នៃអនុសញ្ញានេះ។

២. យន្តការហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងនៅក្នុងមាត្រា ២១ នៃអនុសញ្ញានេះ គឺជាយន្តការសំរាប់ពិធីសារនេះផងដែរ តាមរយៈរចនាសម្ព័ន្ធស្ថាប័នស្របទៅនឹងការអនុវត្តរបស់អនុសញ្ញានេះ។

៣. ទាក់ទងទៅនឹងការកសាងសមត្ថភាព ដែលមានចែងក្នុងមាត្រា ២២ នៃពិធីសារនេះ សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ ដោយផ្តល់ការណែនាំលើយន្តការចែងក្នុងកថាខ័ណ្ឌទី ២ ខាងលើ សំរាប់ពិចារណាដោយសន្និសីទភាគី ត្រូវគិតគូរពីតំរូវការធនធានហិរញ្ញវត្ថុដោយភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍតិចតួចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ជាកោះតូចៗក្នុងចំណោមពួកគេ។

៤. នៅក្នុងអត្ថបទនៃកថាខ័ណ្ឌទី ១ ខាងលើ ភាគីចុះកិច្ចសន្យាត្រូវគិតគូរផងដែរពីតម្រូវការរបស់ភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ជាកោះតូចៗ និងតម្រូវការរបស់ភាគីមានសេដ្ឋកិច្ចអន្តរកាល នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកំណត់ និងអនុវត្តន៍នូវតម្រូវការកសាងសមត្ថភាព របស់ខ្លួនក្នុងគោលបំណងដើម្បីអនុវត្តន៍ពិធីសារនេះ។

៥. ការណែនាំអំពីយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ នៅក្នុងសេចក្តីសំរេចដែលពាក់ព័ន្ធរបស់សន្និសីទភាគី រួមបញ្ចូលការព្រមព្រៀងមុននឹងអនុម័តពិធីសារនេះ ត្រូវអនុវត្តន៍ដោយមានការផ្លាស់ប្តូរសមរម្យចំពោះលក្ខខណ្ឌនៃមាត្រានេះ។

៦. ភាគីប្រទេសអភិវឌ្ឍន៍អាចឧបត្ថម្ភ ហើយភាគីប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីដែលមានសេដ្ឋកិច្ចអន្តរកាលត្រូវត្រៀមខ្លួនទទួលធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសំរាប់ការអនុវត្តលក្ខខណ្ឌនៃពិធីសារនេះ តាមរយៈកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគី។

## មាត្រា ២៩

## សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ

១. សន្និសីទភាគី បំរើជាកិច្ចប្រជុំរបស់ភាគីទាំងអស់ដែលចុះកិច្ចសន្យាទៅនឹងពិធីសារនេះ

២. ភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ដែលមិនមែនជាភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ អាចចូលរួមជាអ្នកសង្កេតការនៅក្នុងដំណើរការកិច្ចប្រជុំណាមួយនៃសន្និសីទភាគី ដែលជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ។ នៅពេលសន្និសីទភាគីនេះ បំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ សេចក្តីសំរេចនៅក្នុងពិធីសារនេះត្រូវធ្វើឡើង ចំពោះតែភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ។

៣. នៅពេលសន្និសីទភាគី បំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ សមាជិកនៃការិយាល័យសន្និសីទភាគីដែលតំណាងអោយភាគីមួយចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ក្នុងខណៈនោះមិនមែនជាភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះទេ ត្រូវជំនួសដោយសមាជិកមួយដែលនឹងត្រូវបានជ្រើសរើសតាំង ក្នុងចំណោមភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ។

៤. សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ ត្រូវធ្វើការត្រួតពិនិត្យឱ្យបានទៀងទាត់លើការអនុវត្តពិធីសារ ហើយត្រូវធ្វើសេចក្តីសំរេចដែលចាំបាច់ដើម្បីជំរុញការអនុវត្ត អោយមានប្រសិទ្ធភាពនៅក្រោមតួនាទីរបស់ខ្លួន។ សន្និសីទភាគី ត្រូវអនុវត្តន៍នូវតួនាទីដែលបានផ្តល់ដោយពិធីសារ និងត្រូវៈ

ក. ផ្តល់អនុសាសន៍ទៅលើបញ្ហាដែលចាំបាច់សំរាប់ការអនុវត្តពិធីសារនេះ

ខ. បង្កើតអនុគណៈកម្មាធិការដែលចាំបាច់សំរាប់ការអនុវត្តពិធីសារនេះ

គ. ស្វែងរក និងប្រើប្រាស់ឱ្យបានសមស្របនូវសេវាកម្ម និងសហប្រតិបត្តិការ និងព័ត៌មានដែលផ្តល់អោយដោយអង្គការអន្តរជាតិ អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានសមត្ថកិច្ច

ឃ. បង្កើតទំរង់ និងកំលាតពេលវេលាសំរាប់ការផ្សព្វផ្សាយព័ត៌មានដែលត្រូវផ្តល់ឱ្យស្របទៅតាមមាត្រា ៣៣ នៃពិធីសារនេះ និងពិចារណាទៅលើព័ត៌មាន និងរបាយការណ៍ដែលដាក់ជូនដោយអនុគណៈកម្មាធិការនេះ។

ង. ពិចារណា និងអនុម័តតាមការចាំបាច់នូវវិសោធនកម្មនៃពិធីសារ និងឧបសម្ព័ន្ធរបស់វា ព្រមទាំងឧបសម្ព័ន្ធបន្ថែមនៃពិធីសារនេះ ដែលចាំបាច់សំរាប់ការអនុវត្តពិធីសារនិង

ច. អនុវត្តនូវតួនាទីនោះ ដែលអាចត្រូវការសំរាប់ការអនុវត្តពិធីសារនេះ។

៥. ច្បាប់នៃនីតិវិធីរបស់សន្និសីទភាគី និងច្បាប់ហិរញ្ញវត្ថុនៃអនុសញ្ញានេះ ត្រូវអនុវត្តន៍អោយបានសមស្របនៅក្រោមពិធីសារនេះ លើកលែងតែមានសេចក្តីសំរេចជាឯកច្ឆ័ន្ទដោយសន្និសីទភាគី ដែលធ្វើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ។

៦. កិច្ចប្រជុំលើកដំបូងនៃសន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវកោះប្រជុំដោយលេខាធិការដ្ឋាន រួមសហការជាមួយកិច្ចប្រជុំលើកដំបូងនៃសន្និសីទភាគី ដែលត្រូវធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ។ កិច្ចប្រជុំសាមញ្ញបន្តបន្ទាប់នៃសន្និសីទភាគី ដែលធ្វើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវធ្វើឡើងរួមសហការជាមួយកិច្ចប្រជុំសាមញ្ញនៃសន្និសីទភាគី ប្រសិនបើគ្មានសេចក្តីសំរេចដោយសន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ។

៧. កិច្ចប្រជុំវិសាមញ្ញនៃសន្និសីទភាគី បំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវធ្វើឡើងនៅពេលផ្សេងទៀត ដែលចាត់ទុកថាជាការចាំបាច់ដោយសន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ឬនៅពេលដែលមានការស្នើសុំជាលាយល័ក្ខអក្សរពីភាគីណាមួយ អោយតែសំណើនេះយ៉ាងហោចណាស់មានសំលេងគាំទ្រ ១/៣ នៃភាគីទាំងអស់ក្នុងរយៈពេល ៦ ខែ ដែលសំណើរនេះត្រូវបានផ្ញើទៅភាគីទាំងនោះដោយលេខាធិការដ្ឋាន។

៨. អង្គការសហប្រជាជាតិ ទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ និងទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ព្រមទាំងប្រទេសភាគីចុះកិច្ចសន្យា និងអ្នកសង្កេតការដែលមិនមែនជាភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ អាចធ្វើជាអ្នកសង្កេតការនៅក្នុងកិច្ចប្រជុំនៃសន្និសីទភាគី បំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ។ អង្គការ ឬទីភ្នាក់ងារណាមួយ ទោះបីជាអង្គការជាតិ ឬអន្តរជាតិ រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលមានចំណេះដឹងក្នុងបញ្ហាទាំងឡាយទាក់ទងទៅនឹងពិធីសារនេះ ហើយដែលបានជូនដំណឹងដល់លេខាធិការដ្ឋាននូវបំណងរបស់ខ្លួននៅក្នុងកិច្ចប្រជុំនៃសន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះក្នុងនាមជាអ្នកសង្កេតការណ៍ អាចត្រូវបានអនុញ្ញាតប្រសិនបើគ្មានការជំទាស់លើសពីសំលេង ១/៣ របស់ភាគីដែលចូលរួមនោះទេ។ ម្យ៉ាងវិញទៀត លើកលែងតែមានចែងនៅក្នុងមាត្រានេះ ការអនុញ្ញាត និងការចូលរួមនៃអ្នកសង្កេតការ ត្រូវផ្អែកទៅលើច្បាប់នៃនីតិវិធីដូចមានចែងក្នុងកថាខ័ណ្ឌទី ៥ ខាងលើ។

## មាត្រា ៣០

## អនុគណៈកម្មាធិការ

១. អនុគណៈកម្មាធិការដែលបង្កើតឡើងក្រោមអនុសញ្ញានេះ ដោយយោលទៅលើសេចក្តីសំរេចនៃសន្និសីទភាគីធ្វើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ បំរើឱ្យពិធីសារនេះក្នុងករណីដែលកិច្ចប្រជុំភាគីត្រូវបញ្ជាក់ច្បាស់លាស់ថាតើមុខងារណាដែលអនុគណៈកម្មាធិការនោះត្រូវអនុវត្តន៏។

២. ភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះដែលមិនមែនជាភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ អាចចូលរួមជាអ្នកសង្កេតការនៅក្នុងដំណើរការនៃកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនោះ។
នៅពេលអនុគណៈកម្មាធិការនៃអនុសញ្ញាបំរើជាអនុគណៈកម្មាធិការនៃពិធីសារនេះ សេចក្តីសំរេចនៅក្រោមពិធីសារត្រូវធ្វើឡើងដោយភាគីចុះកិច្ចសន្យាទៅនឹងពិធីសារតែប៉ុណ្ណោះ។

៣. នៅពេលអនុគណៈកម្មាធិការនៃអនុសញ្ញានេះ បំពេញតួនាទីរបស់ខ្លួន ដែលទាក់ទងទៅនឹងបញ្ហាផ្សេងៗនៃពិធីសារនេះ សមាជិកនៃការិយាល័យរបស់អនុគណៈកម្មាធិការនោះដែលតំណាងឱ្យភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ប៉ុន្តែមិនទាន់ជាភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវបានជំនួសដោយសមាជិកមួយរូប ដែលនឹងត្រូវបានជ្រើសតាំងចេញពីភាគីដែលចុះកិច្ចសន្យាទៅនឹងពិធីសារនេះ។

## មាត្រា ៣១

## លេខាធិការដ្ឋាន

១. លេខាធិការដ្ឋានដែលបង្កើតឡើងដោយមាត្រា ២៤ នៃអនុសញ្ញា ត្រូវដើរតួជាលេខាធិការដ្ឋានបំរើអោយពិធីសារនេះ។

២. មាត្រា ២៤ កថាខ័ណ្ឌទី ១ នៃអនុសញ្ញានេះ ស្តីពីតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននេះ ត្រូវអនុវត្តន៏នូវការផ្លាស់ប្តូរមុខងារ តួនាទីដែលចាំបាច់ឱ្យបានសមរម្យ នៅក្នុងពិធីសានេះ។

៣. ការចំណាយរបស់សេវាកម្មលេខាធិការដ្ឋាននៃពិធីសារនេះ ត្រូវចេញដោយភាគីនានាដោយហេតុថាវាជាលេខាធិការដ្ឋានខុសគ្នា។ សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ នៅក្នុងកិច្ចប្រជុំលើកដំបូងត្រូវសំរេចឱ្យបាននូវការរៀបចំថវិកាចាំបាច់សំរាប់ដល់ទីបញ្ចប់។

មាត្រា ៣២

ទំនាក់ទំនងជាមួយអនុសញ្ញា

"បទបញ្ញត្តិ" នៃអនុសញ្ញានេះទាក់ទងទៅនឹងពិធីសារនៃអនុសញ្ញានេះ ត្រូវអនុវត្តន៍ទៅនឹងពិធីសារនេះ លើកលែងតែមានចែងនៅក្នុងពិធីសារនេះ។

មាត្រា ៣៣

ការតាមឃ្លាំមើល និងការរាយការណ៍

ភាគីនីមួយៗ ត្រូវតាមឃ្លាំមើលការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួននៅក្រោមពិធីសារនេះ និងត្រូវរាយការណ៍ជាទៀងទាត់ដែល កំណត់ដោយសន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ទៅឱ្យសន្និសីទភាគីដែលជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ អំពីវិធានការណ៍ដែលបានយកមកអនុវត្តន៍ពិធីសារនេះ។

មាត្រា ៣៤

ការយល់ព្រមប្រតិបត្តិ

សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ក្នុងកិច្ចប្រជុំលើកដំបូង ត្រូវពិចារណានិងអនុម័តទៅលើនីតិវិធីសហប្រតិបត្តិការ និងយន្តការនៃស្ថាប័នដើម្បីលើកកំពើនការយល់ព្រមប្រតិបត្តិ "បទបញ្ញត្តិ " នៃពិធីសារនេះ និងដើម្បីកំណត់ករណីមិនយល់ព្រមប្រតិបត្តិ។ នីតិវិធី និងយន្តការទាំងនេះ ត្រូវរាប់បញ្ចូលនូវ "បទប្បបញ្ញត្តិ" ទាំងនេះ ដើម្បីផ្តល់យោបល់ ឬជំនួយឱ្យបានសមស្រប។ "បទប្បបញ្ញត្តិ" ទាំងនេះមិនទាក់ទងទៅនឹងនីតិវិធី និងយន្តការក្នុងការដោះស្រាយជម្លោះដែលមានចែងនៅក្នុងមាត្រា ២៧ នៃអនុសញ្ញានេះទេ។

មាត្រា ៣៥

ការវាយតំលៃ និងការពិនិត្យកែសំរួល

សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវធ្វើការវាយតំលៃទៅលើប្រសិទ្ធិភាពនៃពិធីសារនេះ រួមទាំងការវាយតំលៃទៅលើនីតិវិធី និងឧបសម្ព័ន្ធរបស់ពិធីសារនេះ ក្នុងរយៈពេល ៥ឆ្នាំបន្ទាប់ពីបានចូលជាធរមានទៅក្នុងពិធីសារ និងបន្ទាប់ពីនោះយ៉ាងហោចណាស់ត្រូវធ្វើរៀងរាល់ ៥ឆ្នាំម្តង។

មាត្រា ៣៦

ការចុះហត្ថលេខា

ពិធីសារនេះ នឹងត្រូវដាក់ឱ្យចុះហត្ថលេខា នៅឯការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងណៃរ៉ូប៊ី (Nairobi)ដល់ប្រទេស និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០០

និងនៅ ទីចាត់ការអង្គការសហប្រជាជាតិនៅឯទីក្រុងញូយ៉ក (New York) ចាប់ពីថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០០ ដល់ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០០១។

## មាត្រា ៣៧

## ការចូលជាធរមាន

១. ពិធីសារនេះ ត្រូវចូលជាធរមាននៅថ្ងៃទី ៩០ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកលិខិតទី ៥០ផ្តល់សច្ចាប័ន ការព្រមទទួលយក ការឯកភាព ឬការចូលជាសមាជិកដោយប្រទេស ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលជាភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ។

២. ពិធីសារនេះ ត្រូវចូលជាធរមានសំរាប់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលផ្តល់សច្ចាប័ន ការព្រមទទួលយក ឬឯកភាពលើពិធីសារនេះ ឬចូលជាសមាជិកបន្ទាប់ពីការចូលជាធរមានរបស់ខ្លួនដូចដែលបានចែងក្នុង កថាខ័ណ្ឌទី១ ខាងលើថា នៅថ្ងៃទី ៩០ បន្ទាប់ពីនៅថ្ងៃដែលប្រទេស ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នោះ តំកល់ទុកលិខិត នៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ការឯកភាព ឬការចូលជាសមាជិករបស់ខ្លួន ឬក៏នៅថ្ងៃដែលអនុសញ្ញានេះ ចូលជាធរមាននៅក្នុងរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលត្រូវចូលជាធរមានក្រោយគេ។

៣. ចំពោះគោលបំណងនៃកថាខ័ណ្ឌទី១ និងទី២ ខាងលើ រាល់លិខិតតូបករណ៍ដែលបានតំកល់ទុកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ មិនត្រូវបានរាប់បញ្ចូលជាលិខិតបន្ថែម តំកល់ទុកដោយប្រទេសដែលជាសមាជិកនៃអង្គការនេះទេ។

## មាត្រា ៣៨

## ការលើកលែង

គ្មានការលើកលែង អាចរៀបចំធ្វើទៅបានក្នុងពិធីសារនេះទេ។

## មាត្រា ៣៩

## ការដកចេញពីសមាជិកភាព

១. នៅពេលណាក៏ដោយបន្ទាប់ពីរយៈពេល ២ ឆ្នាំ ចាប់ពីពិធីសារនេះចូលជាធរមានសំរាប់ភាគីណាមួយ ភាគីនោះអាចដកខ្លួនចេញពីពិធីសារនេះ ដោយជូនព័ត៌មានជាលាយលក្ខណ៍អក្សរដល់អ្នកទទួលបញ្ញើ។

២. ការដកចេញសមាជិកភាពនោះ ត្រូវធ្វើឡើងនៅពេលផុតកំណត់រយៈពេល ១ ឆ្នាំ បន្ទាប់ពីថ្ងៃដែលអ្នកទទួលបញ្ញើ បានទទួលសេចក្តីជូនព័ត៌មាននោះ ឬនៅថ្ងៃបន្ទាប់ដូចដែលអាចបញ្ជាក់នៅក្នុងសេចក្តីជូនព័ត៌មាននៃការដកសមាជិកភាពចេញ។

## មាត្រា ៤០

## ច្បាប់ដើមនៃពីធីសារ

ច្បាប់ដើមនៃពិធីសារនេះ ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រ៉ុស្ស៊ី និងអេស្ប៉ាញ ដែលមានតំលៃស្មើគ្នា។ ត្រូវតំកល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

ដើម្បីជាសាក្សីក្នុងពិធីសារនេះ ត្រូវមានហត្ថលេខាដែលត្រូវបានផ្តល់សិទ្ធិស្របច្បាប់ ដល់ប្រសិទ្ធភាពដែលបានចុះហត្ថលេខាលើពិធីសារនេះ។

ធ្វើនៅម៉ុងរ៉េអាល់ នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០០០។

## ឧបសម្ព័ន្ធទី ១

## ព័ត៌មានចាំបាច់ក្នុងសេចក្តីជូនព័ត៌មានក្រោមមាត្រា៨ ១០ និង១៣

១. ឈ្មោះ អាស័យដ្ឋាន និងព័ត៌មានលំអិតសំរាប់ទំនាក់ទំនងរបស់អ្នកនាំចេញ

២. ឈ្មោះ អាស័យដ្ឋាន និងព័ត៌មានលំអិតសំរាប់ទំនាក់ទំនងរបស់អ្នកនាំចូល

៣. ឈ្មោះ និងអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់ ព្រមទាំងចំណាត់ថ្នាក់ក្នុងស្រុកនៃកំរិតជីវសុវត្ថិភាព របស់សារពាង្គកាយកែច្នៃរស់ នៅក្នុងប្រទេសនាំចេញ ប្រសិនបើមាន។

៤. កាលបរិច្ឆេទគ្រោងទុក ឬ កាលបរិច្ឆេទនៃចលនាឆ្លងដែន ប្រសិនជាដឹង

៥. ស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ទីកន្លែងនៃការប្រមូល ឬការទទួលយក និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេទាក់ទងទៅនឹងជីវសុវត្ថិភាព។

៦. ប្រភព និងមណ្ឌលនៃសេនេទិចចំរុះរបស់សារពាង្គកាយទទួលយក និង ឬ សារពាង្គកាយមេ ប្រសិនបើដឹង និងការពិពណ៌នាពីដែនជំរកដែលសារពាង្គកាយនេះអាចជំនះ ឬ បង្កើតកូនចៅ

៧. ស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ទីកន្លែងនៃការប្រមូល ឬការទទួលយក និងលក្ខណៈនៃសារពាង្គកាយផ្តល់ឱ្យ ឬសារពាង្គកាយទាក់ទងទៅនឹងជីវសុវត្ថិភាព។

៨. ការពិពណ៌នាពីអាស៊ីតនុយក្លេអ៊ិច ឬការផ្លាស់ប្តូរដែលត្រូវនាំចូលការប្រើប្រាស់បច្ចេកវិជ្ជា និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយកែច្នៃរស់។

៩. ការប្រើប្រាស់ដោយចេតនានៃសារពាង្គកាយកែច្នៃរស់ ឬផលិតផលដែលត្រូវបានកែច្នៃចេញពីសារពាង្គកាយកែច្នៃរស់ដែលមានផ្ទុកនូវធាតុថ្មីដែលទើបរកឃើញនៃសំភារៈសេនេទិចដែលកើតឡើងតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប។

១០. បរិមាណឬទំហំនៃសារពាង្គកាយកែច្នៃរស់ដែលនឹងត្រូវផ្ទេរ។

១១. របាយការណ៍នៃការវាយតំលៃគ្រោះថ្នាក់ពីលើកមុន និងបច្ចុប្បន្នដែលស្របទៅតាមឧបសម្ព័ន្ធ ៣។

១២. វិធីសាស្ត្រដែលបានស្នើសំរាប់គ្រប់គ្រង ការរក្សាទុក ការផ្ទេរ ការដឹកជញ្ជូន និងការប្រើប្រាស់ប្រកបដោយសុវត្ថិភាព រួមបញ្ចូលវិធីសាស្ត្រវិចខ្ចប់ បិទស្លាកសញ្ញា ចែកចាយ ការបោះចោលយកទៅចោល បែបបទ និងនិតិវិធីគ្រាអាសន្នឲ្យបានសមស្រប។

១៣. ស្ថានភាពច្បាប់នៃសារពាង្គកាយកែច្នៃរស់នៅក្នុងប្រទេសនាំចេញ (ឧទាហរណ៍ ប្រសិនបើមានការហាមឃាត់ក្នុងការនាំចេញ ការដាក់កំហិតផ្សេងទៀត ឬមានការឯកភាពចំពោះការអោយចេញជាទូទៅ) ហើយប្រសិនបើសារពាង្គកាយកែច្នៃរស់ ត្រូវហាមឃាត់នៅក្នុងប្រទេសនាំចេញ មូលហេតុ ឬ មូលហេតុសំរាប់ការហាមឃាត់។

១៤. លទ្ធផល និងគោលបំណងនៃសេចក្តីជូនព័ត៌មានដោយអ្នកនាំចេញទៅប្រទេសផ្សេងទៀត ស្តីពីសារពាង្គកាយកែច្នៃរស់ ដែលនឹងត្រូវផ្ទេរ។

១៥. ការបញ្ជាក់ថាព័ត៌មានខាងលើពិតជាត្រឹមត្រូវ។

# ឧបសម្ព័ន្ធទី ២

## ព័ត៌មានចាំបាច់ទាក់ទងទៅនឹងសារពាង្គកាយកែច្នៃរស់ សំរាប់ប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬ សំរាប់ការកែច្នៃ ចែងក្នុងមាត្រា ១១

ក. ឈ្មោះ និងព័ត៌មានលំអិតសំរាប់ទំនាក់ទំនង របស់អ្នកដាក់ពាក្យសុំសំរាប់ធ្វើសេចក្តីសំរេចលើការប្រើប្រាស់ ក្នុងស្រុក

ខ. ឈ្មោះ និងព័ត៌មានលំអិតសំរាប់ទំនាក់ទំនង របស់អាជ្ញាធរទទួលខុសត្រូវចំពោះសេចក្តីសំរេចនេះ

គ. ឈ្មោះ និងអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់

ឃ. ការពិពណ៌នាពីផ្លាស់ប្តូរសែន បច្ចេកទេសដែលគេប្រើប្រាស់ និងបុគ្គលិកលក្ខណៈដែលជាលទ្ធផលនៃសារពាង្គកាយកែច្នៃរស់

ង. អត្តសញ្ញាណកម្មពិសេសនៃសារពាង្គកាយកែច្នៃរស់

ច. ស្ថានភាពនៃការកំណត់ពូជ ឈ្មោះធម្មតា ទីកន្លែងនៃការប្រមូលផ្តុំ ឬទីកន្លែងនៃការទទួលយក និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេទាក់ទងទៅនឹងជីវសុវត្ថិភាព។

ឆ. ប្រភពដើមកំណើត និងមជ្ឈមណ្ឌលសេនេទិចបើស្គាល់ នៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេ និងការពណ៌នាពីដែនជំរកដែលសារពាង្គកាយនេះអាចជំនះ ឬបង្កើតកូនចៅបាន។

ជ. ស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ទីកន្លែងនៃការប្រមូលផ្តុំ ឬទីកន្លែងនៃការទទួលយក និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយផ្តល់ឱ្យ ឬសារពាង្គកាយទាក់ទងទៅនឹងជីវសុវត្ថិភាព។

ឈ. ការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ដែលបានឯកភាព

ញ. របាយការណ៍វាយតំលៃពីគ្រោះថ្នាក់ ដែលស្របទៅនឹងឧបសម្ព័ន្ធទី ៣

ដ. វិធីសាស្ត្រដែលស្នើឡើងសំរាប់ការគ្រប់គ្រង ការថែរក្សា ដឹកជញ្ជូន និងប្រើប្រាស់អោយមានសុវត្ថិភាព រួមទាំងវិធីសាស្ត្រវិចខ្ចប់ ដាក់ផ្លាក់សញ្ញា ចែកចាយ យកទៅចោល និងវិធីសាស្ត្របំរុងសមស្រប។

# ឧបសម្ព័ន្ធទី ៣

## ការវាយតំលៃហានិភ័យ

### គោលបំណង

១. គោលបំណងនៃការវាយតំលៃហានិភ័យនៅក្នុងពិធីសារនេះគឺដើម្បីធ្វើអត្តសញ្ញាណកម្មនិងវាយតំលៃផលប៉ះពាល់ដ៏បូងនៃសារពាង្គកាយកែច្នៃរស់ លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តភាពនៃជីវៈចម្រុះ នៅក្នុងបរិស្ថានដែលទំនងជា ទទួលផលប៉ះពាល់ខ្លាំង ប្រមទាំងគិតគូរផងដែរពីហានិភ័យទាំងឡាយដល់សុខភាពមនុស្ស។

### ការប្រើប្រាស់ការវាយតំលៃហានិភ័យ

២. ការវាយតំលៃហានិភ័យដែលត្រូវបានអនុវត្តន៍ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើសេចក្តីសំរេចក្នុងការជូនព័ត៌មានស្តីពីសារពាង្គកាយកែច្នៃរស់។

### គោលការណ៍ទូទៅ

៣. ការវាយតំលៃហានិភ័យ ត្រូវអនុវត្តន៍អោយបានត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ និងមានតម្លាភាព ហើយត្រូវបញ្ចូលយោបល់របស់ជំនាញការ និងគោលការណ៍ណែនាំដែលរៀបចំដោយអង្គការអន្តរជាតិពាក់ព័ន្ធនានា។

៤. ការខ្វះខាតចំណេះដឹងខាងវិទ្យាសាស្ត្រ ឬការឯកភាពផ្នែកវិទ្យាសាស្ត្រ មិនចាំបាច់ត្រូវបកស្រាយដូចដែលបានបង្ហាញពីកំរិតពិសេសនៃហានិភ័យ អវត្តមានហានិភ័យ ឬក៏ហានិភ័យដែលអាចទទួលយកបាន។

៥. ហានិភ័យដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ឬផលិតផលកែច្នៃចេញពីសារពាង្គកាយកែច្នៃរស់ ដែលផ្ទុកនូវធាតុផ្សំរកឃើញថ្មីៗនៃសំភារៈសេនេទិច ដែលទទួលបានតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើបត្រូវបានគេគិតគូរនៅក្នុងបរិបទនៃហានិភ័យដែលបង្កឡើងដោយសារពាង្គកាយមិនទទួលយក ឬសារពាង្គកាយមេនៅក្នុងបរិស្ថាន ដែលទំនងជាទទួលផលប៉ះពាល់ខ្លាំង។

៦. ការវាយតំលៃហានិភ័យត្រូវអនុវត្តន៍លើមូលដ្ឋានការពិតជាក់ស្តែងនីមួយៗ។ ព័ត៌មានដែលត្រូវការចាំបាច់អាចប្រែប្រួលទៅតាមលក្ខណៈធម្មជាតិ និងកំរិតលំអិតពីករណីមួយទៅករណីមួយទៀត អាស្រ័យទៅលើសារពាង្គកាយកែច្នៃរស់ ពាក់ព័ន្ធការប្រើប្រាស់ដោយចេតនា និងបរិស្ថានដែលទំនងជាទទួលផលប៉ះពាល់ខ្លាំង។

### វិធីសាស្ត្រ

៧. ដំណើរការនៃការវាយតំលៃហានិភ័យ អាចផ្តល់នូវតំរូវការព័ត៌មានបន្ថែមអំពីប្រធានបទជាក់លាក់ ដែលអាចត្រូវបានកំណត់ និងស្នើឡើងក្នុងកំឡុងពេលដំណើរការវាយតំលៃនេះ ផ្ទុយទៅវិញព័ត៌មានអំពីប្រធានបទផ្សេងទៀត អាចមិនពាក់ព័ន្ធ នៅក្នុងករណីខ្លះៗទៀត។

៨. ដើម្បីបំពេញគោលបំណងរបស់ពិធីសារនេះ ការវាយតំលៃហានិភ័យទាមទារនូវជំហានសមស្របដូចខាងក្រោម:

ក. អត្តសញ្ញាណកម្មនៃលក្ខណៈសេណូទីប (Genotypic) និងផេណូទីប (Phenotypic) ភ្ជាប់ជាមួយនឹងសារពាង្គកាយកែច្នៃរស់ដែលអាចមានឥទ្ធិពលអវិជ្ជមានទៅលើជីវៈចម្រុះនៅក្នុងបរិស្ថានដែលទំនងជាទទួលផលប៉ះពាល់ខ្លាំងដោយគិតគូរផងដែរទៅលើហានិភ័យដល់សុខភាពមនុស្ស។

ខ. ការវាយតំលៃពីកំរិតនៃឥទ្ធិពលអវិជ្ជមានទាំងនេះដែលត្រូវបានទទួលស្គាល់ ដោយគិតគូរពីកំរិត និងប្រភេទបញ្ចេញចោលទៅក្នុងបរិស្ថាន ដែលទទួលផលប៉ះពាល់ខ្លាំងនៃសារពាង្គកាយកែច្នៃរស់។

គ. ការវាយតំលៃពីផលវិបាកដែលបង្កើតនូវឥទ្ធិពលអាក្រក់

ឃ. ការប៉ាន់ស្មាននៃហានិភ័យទាំងមូលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ដោយមានមូលដ្ឋានលើការវាយតំលៃលើកំរិត និងវិបាកនៃឥទ្ធិពលអាក្រក់ចេញពីសារពាង្គកាយនោះ។

ង. អនុសាសន៍ថាតើហានិភ័យនេះអាចទទួលយកបាន ឬអាចគ្រប់គងបានដែរឬទេ រួមទាំងអត្តសញ្ញាណកម្មនៃយុទ្ធសាស្ត្រចាំបាច់ ដើម្បីគ្រប់គ្រងនូវហានិភ័យទាំងនេះ។

ច. នៅពេលមានភាពមិនច្បាស់លាស់ទាក់ទិនទៅនឹងកំរិតនៃហានិភ័យ វាអាចត្រូវបានបកស្រាយដោយស្នើសុំព័ត៌មានបន្ថែមលើបញ្ហាពាក់ព័ន្ធ ឬដោយអនុវត្តន៍នូវយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ សមរម្យ ឬដោយតាមឃ្លាំមើលសារពាង្គកាយកែច្នៃរស់ នៅក្នុងបរិស្ថានដែលទំនងជាទទួលផលប៉ះពាល់ខ្លាំង។

ចំណុចដែលត្រូវ លើកយកមកពិចារណា:

៩. ផ្អែកទៅលើករណីនេះ ការវាយតំលៃពីហានិភ័យត្រូវគិតគូរដល់សេចក្តីលំអិតនៃបច្ចេកទេស និងវិទ្យាសាស្ត្រពាក់ព័ន្ធលើបុគ្គលិកលក្ខណៈនៃប្រធានបទខាងក្រោម:

**ក. <u>សារពាង្គកាយទទួលយកឬ សារពាង្គកាយមេ:</u>** បុគ្គលិកលក្ខណៈជីវសាស្ត្រនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេ រួមមានព័ត៌មានស្តីពីស្ថានភាពនៃការកំណត់ពូជអំបូរ ឈ្មោះធម្មតា ដើមកំណើត ប្រភពដើមកំណើត និងមជ្ឈមណ្ឌលសេនេទិចចម្រុះបើដឹង និងការពិពណ៌នាពីដែនជំរកដែលសារពាង្គកាយនោះ អាចជំនះ ឬបង្កើតកូនចៅបាន។

**ខ. <u>សារពាង្គកាយផ្តល់អោយមួយ ឬច្រើន:</u>** ស្ថានភាពនៃការកំណត់ពូជអំបូរ និងឈ្មោះធម្មតា ប្រភពនិងបុគ្គលិកលក្ខណៈជីវសាស្ត្រពាក់ព័ន្ធ នៃសារពាង្គកាយផ្តល់អោយ។

**គ. <u>ភ្នាក់ងារចំលងរោគ (Vector):</u>** បុគ្គលិកលក្ខណៈនៃភ្នាក់ងារចំលងរោគ រួមទាំងអិនភាគរបស់វាប្រភពដើមកំណើត និងទំហំនៃដែនជំរក ប្រសិនបើកើតមាន។

**ឃ. <u>ការបញ្ចូល ឬ /និងបុគ្គលិកលក្ខណៈនៃការផ្លាស់ប្តូរ:</u>** បុគ្គលិកលក្ខណៈសេនេទិចនៃអាស៊ីតនុយក្លេអ៊ិចដែលត្រូវបានបញ្ចូល ឬ/ និងតួនាទីដែលបានបញ្ជាក់ និងបុគ្គលិកលក្ខណៈនៃការផ្លាស់ប្តូរដែលត្រូវបានបង្ហាញ។

**ង. <u>សារពាង្គកាយកែច្នៃរស់:</u>** លក្ខណៈសំគាល់នៃសារពាង្គកាយកែច្នៃរស់ ព្រមទាំងភាពខុសគ្នារវាងលក្ខណៈជីវសាស្ត្រនៃសារពាង្គកាយកែច្នៃរស់ និងលក្ខណៈជីវសាស្ត្រនៃសារពាង្គកាយទទួលយក ឬសារពាង្គកាយមេ។

**ច. <u>ការរុករក និងការធ្វើអត្តសញ្ញាណកម្មនៃសារពាង្គកាយកែច្នៃរស់:</u>** វិធីសាស្ត្រនៃការរុករក និងការធ្វើអត្តសញ្ញាណកម្មនៃសារពាង្គកាយកែច្នៃរស់ និងភាពខុសគ្នារវាងបុគ្គលិកលក្ខណៈជីវសាស្ត្រនៃសារពាង្គកាយកែច្នៃរស់ និងសារពាង្គកាយទទួលយកទាំងនោះ ឬ សារពាង្គកាយមេ។

**ឆ. <u>ព័ត៌មានដែលទាក់ទងទៅនឹងការប្រើប្រាស់ដោយចេតនា:</u>** ព័ត៌មានដែលទាក់ទងទៅនឹងការប្រើប្រាស់ដោយចេតនានៃសារពាង្គកាយកែច្នៃរស់ រួមមានការប្រើប្រាស់ថ្មី ឬការប្រើប្រាស់ដែលត្រូវផ្លាស់ប្តូរ ប្រៀបធៀបទៅនឹងសារពាង្គកាយទទួលយក ឬ សារពាង្គកាយមេ។

**ជ. <u>បរិស្ថានដែលទទួលយក:</u>** ព័ត៌មានស្តីពីបុគ្គលិកលក្ខណៈទីតាំងភូមិសាស្ត្រ អាកាសធាតុ និងអេកូឡូស៊ី រួមបញ្ចូលព័ត៌មានដែលទាក់ទងនៅលើជីវៈចម្រុះ
និងប្រភពដើមកំណើតនៃបរិស្ថានដែលទំនងជាទទួលផលប៉ះពាល់ខ្លាំង។